**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**
សំណុំរឿងព្រហ្មទណ្ឌលេខៈ ៨៧០
ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២
សំណុំរឿងស៊ើបសួរលេខៈ ៧២៨ ម.ឌ
ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២
សំណុំរឿងជំនុំជម្រះលេខៈ ៩៩៤
ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២
**សាលក្រមព្រហ្មទណ្ឌលេខៈ ១២១/១០ ក្រ១"ជ"**
ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះសីហនុ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាដំបូងខេត្តព្រះសីហនុ
នាថ្ងៃពុធ ៨កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣
ដោយមានសមាសភាពជំនុំជម្រះដូចតទៅៈ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**ចៅក្រមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តព្រះសីហនុ
លោក អនុប្រធានសាលាដំបូងខេត្តព្រះសីហនុ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តព្រះសីហនុ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៨៧០ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ ដែលមានៈ

១. ឈ្មោះ [redacted] LIN JIAN ភេទប្រុស អាយុ៣៦ឆ្នាំ កើតឆ្នាំ១៩៨៦ ជនជាតិចិន ទីកន្លែងកំណើតនៅ [redacted] ប្រទេសចិន ទីលំនៅបណ្តោះអាសន្នមុនពេលឃាត់ខ្លួននៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មុខរបរ អ្នកកត់ត្រាបុគ្គលិកចេញ-ចូល កម្រិតវប្បធម៌ ថ្នាក់ទី៧ ឪពុកឈ្មោះ [redacted] ZHEN QIU "រ" ម្តាយឈ្មោះ [redacted] YEU MEI "រ" ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន **គ្មាន**។ (ក្នុងឃុំ)

***(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ១២៥២ ជ.ប.ឃ.ឌ/ឃ/២២ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២)***

២. ឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN ភេទប្រុស អាយុ៣៩ឆ្នាំ កើតឆ្នាំ១៩៨៣ ជនជាតិចិន ទីកន្លែងកំណើតនៅខេត្តជាំងស៊ី ប្រទេសចិន ទីលំនៅបណ្តោះអាសន្នមុនពេលឃាត់ខ្លួននៅភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មុខរបរ អ្នកគ្រប់គ្រងបុគ្គលិកក្រុមហ៊ុន ខាយប៉ កម្រិតវប្បធម៌ ថ្នាក់ទី៧ ឪពុកឈ្មោះ [redacted] JING JUN "រ" ម្តាយឈ្មោះ [redacted] YAN "រ" ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន **គ្មាន**។ (ក្នុងឃុំ)

***(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ១២៥៣ ជ.ប.ឃ.ឌ/ឃ/២២ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២)***



Scanned with CamScanner

៣. ឈ្មោះ [redacted] XIANG QUAN ភេទប្រុស អាយុ៣១ឆ្នាំ កើតឆ្នាំ១៩៩១ ជនជាតិចិន ទីកន្លែងកំណើតនៅ[redacted] ប្រទេសចិន ទីលំនៅបណ្ដោះអាសន្នមុនពេលឃាត់ខ្លួននៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មុខរបរ បុគ្គលិកក្រុមហ៊ុនផ្នែកទិញឥវ៉ាន់ កម្រិតវប្បធម៌ ថ្នាក់ទី៧ ឪពុកឈ្មោះ មិនស្គាល់ឈ្មោះ "ស" ម្ដាយឈ្មោះ [redacted] MAN QING "រ" ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសពីមុន **គ្មាន**។ (ក្នុងឃុំ)

*(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ១២៥៤ ដ.ប.ឃ.ឧ/ឃ/២២ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២)*

៤. ឈ្មោះ [redacted] XIANG PING ភេទប្រុស អាយុ២៨ឆ្នាំ កើតឆ្នាំ១៩៩៤ ជនជាតិចិន ទីកន្លែងកំណើតនៅខេត្តហ្វូចៀន ប្រទេសចិន ទីលំនៅបណ្ដោះអាសន្នមុនពេលឃាត់ខ្លួននៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មុខរបរ អ្នកគ្រប់គ្រងការស្នាក់នៅរបស់បុគ្គលិក កម្រិតវប្បធម៌ ថ្នាក់ទី៧ ឪពុកឈ្មោះ មិនស្គាល់ឈ្មោះ "ស" ម្ដាយឈ្មោះ [redacted] MAN QING "រ" ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសពីមុន **គ្មាន**។ (ក្នុងឃុំ)

*(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ១២៥៥ ដ.ប.ឃ.ឧ/ឃ/២២ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២)*

៥. ឈ្មោះ [redacted] QIAO LONG ភេទប្រុស អាយុ២៩ឆ្នាំ កើតឆ្នាំ១៩៩៣ ជនជាតិចិន ទីកន្លែងកំណើតនៅខេត្ត[redacted] ប្រទេសចិន ទីលំនៅបណ្ដោះអាសន្នមុនពេលឃាត់ខ្លួននៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មុខរបរ អ្នកកត់ត្រាបុគ្គលិកចូលធ្វើការ កម្រិតវប្បធម៌ ថ្នាក់ទី១២ ឪពុកឈ្មោះ [redacted] WEN HE "រ" ម្ដាយឈ្មោះ [redacted] QING HUA "រ" ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសពីមុន **គ្មាន**។ (ក្នុងឃុំ)

*(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ១២៥៦ ដ.ប.ឃ.ឧ/ឃ/២២ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២)*

ជាប់ចោទពីបទៈ **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់** បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាម **មាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌ**, បទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាម**មាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ** និងបទៈ **អំពើលក់-ដូរមនុស្សដោយមានគោលដៅ** បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាម**មាត្រា១៥ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុន ជឹងឆាយ៥ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។

៦. ឈ្មោះ [redacted] XIANKANG ភេទប្រុស កើតថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៨០ ជនជាតិចិន ទីកន្លែងមានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ២៣៩ ផ្លូវលេខ២៧៧ ភូមិចោមចៅ២ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មុខរបរ គ្រូបង្រៀន កាន់លិខិតឆ្លងដែនលេខៈ E05665850។ **(គេចខ្លួន)**

ជាប់ចោទពីបទៈ **អំពើលក់-ដូរមនុស្សដោយមានគោលដៅ** បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាម**មាត្រា១៥ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ** និងបទៈ **សម្អាតប្រាក់** បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាម**មាត្រា៣៨ នៃច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មខេត្តព្រះសីហនុ កាលពីអំឡុងឆ្នាំ២០២២**។

<u>មេធាវីការពារសិទ្ធិ</u>

១.លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] BING LONG ហៅ AH TIAN។

២.លោក [redacted] ជាសហមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] XIANG QUAN, ឈ្មោះ [redacted] XIANG PING, ឈ្មោះ [redacted] LIN JIAN និងឈ្មោះ [redacted] QIAO LONG។

៣. លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] XIANKANG។



Scanned with CamScanner

៤. លោក [redacted] ជាសហមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] BING LONG ហៅ AH TIAN។

៥. លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] XIANG QUAN, ឈ្មោះ [redacted] XIANG PING, ឈ្មោះ [redacted] LIN JIAN និងឈ្មោះ [redacted] QIAO LONG។

**អ្នកបកប្រែ**

លោក [redacted] **ហ៊ាងផេង** ជាអ្នកបកប្រែ។

- បានឃើញ របាយការណ៍សំយោគលេខៈ ៦៩៤ រ.ប.ក/២២ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគបាលខេត្តព្រះសីហនុ។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ ៧១៨ អ.យ.ង/២២ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។
- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៨៨៦ អ.យ.ង/២២ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។
- បានឃើញ ដីកាដំណោះស្រាយលេខៈ ៤៤៤ ដ.ដ.ស/ជ/២២ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ របស់សាលាដំបូងខេត្តព្រះសីហនុ។
- បានឃើញ ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខៈ ៦៣៤ ត.ព.វ/២៣ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ។

## អង្គហេតុនៃរឿងមានដូចតទៅ៖

តាមរយៈរបាយការណ៍លេខ ៦៩៤ រ.ប.ក/២២ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានឱ្យដឹងថាកាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ១៧៖០០នាទី កម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានចុះទៅដល់ទីតាំងក្រុមហ៊ុន ជឹងឆាយ៥ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដើម្បីស្វែងរកជនរងគ្រោះមានឈ្មោះ [redacted] JIA XU ភេទស្រី អាយុ៣១ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted] YONG GUI ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិចិន។ ដោយមានការសហការពីម្ចាស់ទីតាំងក៏បាននាំសមត្ថកិច្ចទៅជួបជាមួយនឹងជនរងគ្រោះទាំងពីរនាក់នោះ រួចហើយសមត្ថកិច្ចក៏បានឆែកឆេរបន្ទប់ការិយាល័យជាន់ទី៧ រកឃើញដំបងឆក់ ០១ដើម និងខ្នោះដៃ ០២គូ មានកូនសោរខ្នោះ ០២ ដោយសមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យបានចំនួន ០៤ នាក់រួមមាន ១/ឈ្មោះ [redacted] XIANG QUAN ភេទប្រុស អាយុ៣១ឆ្នាំ កើតឆ្នាំ១៩៩១ ជនជាតិចិន ២/ឈ្មោះ [redacted] QIAO LONG ភេទប្រុស អាយុ២៩ឆ្នាំ កើតឆ្នាំ១៩៩៣ ជនជាតិចិន ៣/ឈ្មោះ [redacted] XIANG QUAN ភេទប្រុស អាយុ៣១ឆ្នាំ កើតឆ្នាំ១៩៩១ ជនជាតិចិន ៤/ឈ្មោះ [redacted] LIN JIAN ភេទប្រុស អាយុ៣៦ឆ្នាំ កើតឆ្នាំ១៩៨៦ ជនជាតិចិន។ បន្ទាប់ពីបានឃាត់ខ្លួនជនសង្ស័យ និងនាំជនរងគ្រោះមកសាកសួររួចហើយ ជនរងគ្រោះទាំងពីរនាក់បានបញ្ជាក់ថាកាលពីអំឡុងខែមេសា ឆ្នាំ២០២២ ខ្លួនទាំងពីរនាក់ប្ដីប្រពន្ធបានដើរទៅហូបបាយនៅឆ្នេរសមុទ្រ ក៏ស្រាប់តែមានជនសង្ស័យមួយក្រុមមានគ្នា ០៣នាក់បានចាប់ខ្លួនទាំងពីរនាក់ប្ដីប្រពន្ធយកទៅអាគារក្រុមហ៊ុន ខាយប៉ ដោយមានជនសង្ស័យឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN ភេទប្រុស អាយុ៣៩ឆ្នាំ កើតឆ្នាំ១៩៨៣ ជនជាតិចិន ជាអ្នកគ្រប់គ្រង បានឱ្យជនរងគ្រោះធ្វើការបានតែរយៈពេល ០២ ថ្ងៃ ពេលខ្លួនមិនព្រមធ្វើការឱ្យក្រុមហ៊ុនក៏ត្រូវបានជនសង្ស័យវាយធ្វើបាបដោយប្រើដៃនិងជើង រួចហើយខាងក្រុមហ៊ុន៕

ខាយប៉ បានលក់ពួកខ្លួនទៅឱ្យក្រុមហ៊ុន ជឹងឆាយ៥ ដោយមានជនសង្ស័យឈ្មោះ [redacted] XIANG PING ភេទប្រុស អាយុ២៨ឆ្នាំ កើតឆ្នាំ១៩៩៤ ជនជាតិចិន ជាអ្នកបើកបររថយន្តដឹកពួកខ្លួនយកទៅធ្វើការនៅក្រុមហ៊ុន ជឹងឆាយ៥ ដែលមានឈ្មោះ [redacted] QIAO LONG ជាអ្នកគ្រប់គ្រងបានបញ្ជាឱ្យឈ្មោះ [redacted] XIANG QUAN និងឈ្មោះ [redacted] XIANG PING យកជនរងគ្រោះទៅឃុំទុកនៅក្នុងបន្ទប់លេខ ៥០២ រួចបង្ខំឱ្យពួកខ្លួនធ្វើការ ពេលដែលពួកខ្លួនមិនព្រមធ្វើការពួកគេក៏បានវាយធ្វើបាបលើរូបរាងកាយរបស់ជនរងគ្រោះ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ក្រុមហ៊ុន ជឹងឆាយ៥ ក៏បានលក់ជនរងគ្រោះទាំងពីរនាក់ប្តីប្រពន្ធទៅក្រុមហ៊ុន ជាវសានទីង ទៀតដោយមានជនសង្ស័យឈ្មោះ [redacted] LIN JIAN ជាអ្នកដឹកជញ្ជូនជនរងគ្រោះពីក្រុមហ៊ុន ជាវសានទីង មក ក្រុមហ៊ុន ជឹងឆាយ៥វិញ ក៏ត្រូវបានសមត្ថកិច្ចស្ទាក់ចាប់បានតែម្តង។ អំឡុងពេលដែលសមត្ថកិច្ចចុះបង្ក្រាប ដល់ទីតាំងក្រុមហ៊ុន ជឹងឆាយ៥ ក៏មានជនរងគ្រោះម្នាក់ទៀតឈ្មោះ [redacted] YAN ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិចិន បានដាក់ពាក្យបណ្តឹងអះអាងថាខ្លួនគេក៏ត្រូវបានជនសង្ស័យចាប់មកបង្ខាំងធ្វើការនៅក្រុមហ៊ុនដែរ។ ក្រោយពីសមត្ថកិច្ចបានធ្វើការនាំជនរងគ្រោះមកសាកសួរ និងបានឃាត់ខ្លួនជនសង្ស័យមកសាកសួររួចហើយ ឃើញថាករណីដែលបង្ក្រាបខាងលើនេះមានពាក់ព័ន្ធនឹងជនសង្ស័យចំនួន ០៥នាក់រួមមាន ១/ឈ្មោះ [redacted] LIN JIAN ភេទប្រុស អាយុ៣៦ឆ្នាំ កើតឆ្នាំ១៩៨៦ ជនជាតិចិន ២/ឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN ភេទប្រុស អាយុ៣៩ឆ្នាំ កើតឆ្នាំ១៩៨៣ ជនជាតិចិន ៣/ឈ្មោះ [redacted] XIANG QUAN ភេទប្រុស អាយុ៣១ឆ្នាំ កើតឆ្នាំ១៩៩១ ជនជាតិចិន ៤/ឈ្មោះ [redacted] XIANG PING ភេទប្រុស អាយុ២៨ឆ្នាំ កើតឆ្នាំ១៩៩៤ ជនជាតិចិន ៥/ឈ្មោះ [redacted] QIAO LONG ភេទប្រុស អាយុ២៩ឆ្នាំ កើតឆ្នាំ១៩៩៣ ជនជាតិចិន ព្រមទាំងដកហូត បានរថយន្តមួយគ្រឿងម៉ាក PORSCHE ពណ៌ខ្មៅ ពាក់ផ្លាកលេខ 2AG-0667 ដែលជាកម្មសិទ្ធិរបស់ជនត្រូវចោទ ឈ្មោះ [redacted] XIANKANG ដែលជាបក្ខពួក ក្នុងអំពើលក់ដូរមនុស្ស និងជាសម្ភារៈសម្រាប់ធ្វើសកម្មភាព លក់ដូរមនុស្សដោយខុសច្បាប់ថែមទៀតផង។ ក្រោយពីមន្ត្រីនគរបាលយុត្តិធម៌បានសាកសួរលើជនសង្ស័យ រួចហើយក៏បានកសាងសំណុំរឿង បញ្ជូនជនសង្ស័យព្រមទាំងវត្ថុតាងមកតុលាការដើម្បីចាត់ការតាមនីតិវិធី។

## នាពេលសវនាការ

តុលាការឱ្យក្រឡាបញ្ជីរាយការណ៍ពីវត្តមាន

ក្រឡាបញ្ជីរាយការណ៍អំពីវត្តមាន

តុលាការសួរយោបល់តំណាងអយ្យការ និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

តំណាងអយ្យការ និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើតុលាការឱ្យបន្តនីតិវិធី

តុលាការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនជាប់ចោទ

តុលាការប្រាប់សិទ្ធិ និងបទចោទប្រកាន់ដល់ជនជាប់ចោទ

ជនជាប់ចោទទទួលយកលោក [redacted] ហ៊ាងផេង ជាអ្នកបកប្រែ។

- អំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] JIA XU នៅជំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌បាន ឱ្យដឹងថា៖ កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩ ខ្លួនបានមកដល់ប្រទេសកម្ពុជាដោយជិះយន្តហោះពីខេត្ត គួងចូវ ប្រទេសចិន មកចុះនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ និងបានបន្តដំណើរមកខេត្តព្រះសីហនុ ដើម្បីទេសចរណ៍។ នៅក្នុងអំឡុងខែមេសា ឆ្នាំ២០២២ ខ្លួននិងប្តីរបស់ខ្លួនឈ្មោះ [redacted] YONG GUI ជនជាតិចិន បានស្នាក់នៅក្នុងសណ្ឋាគារ វិមានខ្សាច់ស នៅពាក់កណ្តាលយប់មិនចាំម៉ោង ខ្លួននិងប្តីរបស់ខ្លួនបានដើរចេញ ពីសណ្ឋាគារទៅហូបបាយនៅឆ្នេរសមុទ្រអូរឈើទាលដែលនៅទល់មុខសណ្ឋាគារ។ ពេលដើរតាមផ្លូវក៏ស្រាប់តែ៚



Scanned with CamScanner

មានរថយន្ត ០១គ្រឿង ម៉ាក ស្តារិច ពណ៌ខ្មៅ មិនចាំស្លាកលេខ បានជិះមកពីក្រោយពួកខ្លួនហើយក៏មានជនជាតិចិន ០៣នាក់ បានចុះពីលើរថយន្តស្ទុះមកចាប់ខ្លួនឡើងរថយន្តពេលនោះប្ដីរបស់ខ្លួនបានឃើញក៏បានស្ទុះមកជួយខ្លួន ស្រាប់តែមានជនជាតិចិន ០២នាក់ទៀតបានចុះមកពីរថយន្តដដែលនោះមកចាប់ខ្លួន និងប្ដីរបស់ខ្លួន ឡើងរថយន្តទាំងអស់គ្នាតែម្ដង នៅក្នុងរថយន្តនោះជនសង្ស័យមានគ្នា ០៥នាក់ ជាជនជាតិចិនទាំងអស់ពេលដែលពួកវាចាប់ពួកខ្លួនឡើងរថយន្តហើយ ពួកវាបានវាយខ្លួន និងប្ដីរបស់ខ្លួននៅក្នុងរថយន្តហើយ ពួកវាបានដកយកទូរស័ព្ទដៃរបស់ពួកខ្លួនរួចបានដឹកពួកខ្លួនយកទៅក្រុមហ៊ុន ឆាយណាថោន ហើយពួកវាបានឃុំពួកខ្លួនទាំង០២នាក់ ក្នុងអគារ ខាយប៉ មិនចាំលេខអគារ បន្ទប់លេខ ៣០៣ ដើម្បីបង្ខំឱ្យពួកខ្លួនធ្វើការងារអនឡាញនៅទីនោះ។ រំលងបាន ០២ថ្ងៃគឺខាងក្រុមហ៊ុនបានអោយខ្លួន និងប្ដីរបស់ខ្លួនចាប់ផ្ដើមធ្វើការងារផ្នែកកំព្យូទ័រនៅអាគារទី៥ ជាន់ទី១, បន្ទប់លេខ ១០៣ តែខាងក្រុមហ៊ុនមិនបានអោយប្រាក់ខែពួកខ្លួនទេ។ ហើយនៅពេលដែលពួកខ្លួន មិនព្រមធ្វើការងារអោយក្រុមហ៊ុន ឈ្មោះ [redacted] BING LONG ភេទប្រុស ជាអ្នកគ្រប់គ្រង បានវាយធ្វើបាបពួកខ្លួនដោយប្រើដៃ-ជើង និងបានយកដំបងឆក់មកឆក់ប្ដីរបស់ខ្លួន ហើយពួកវាបានវាយខ្លួនឡើងហើមមុខហើមមាត់ ហើយបានគំរាមពួកខ្លួនថា បើពួកខ្លួនមិនធ្វើការឱ្យក្រុមហ៊ុនទេ ពួកវានឹងវាយធ្វើបាបពួកខ្លួនទៀត បន្ទាប់មកពួកវាបានយកខ្លួន និងប្ដីរបស់ខ្លួនទៅឃុំទុកនៅបន្ទប់ផ្សេងពីគ្នាហើយ ពួកវាបានឱ្យបក្ខពួករបស់ពួកវា ០២នាក់ ម្នាក់ជាជនជាតិចិន ភេទប្រុស និងម្នាក់ទៀត ជាជនជាតិម៉ាឡេស៊ី យកខ្នោះដៃមកដាក់ពួកខ្លួនជាប់នឹងគ្រែដេក ដោយពួកខ្លួនមិនអាចធ្វើអ្វីបានទើបបង្ខំចិត្តព្រមធ្វើការឱ្យពួកវា។ នៅអំឡុងខែមិថុនា ឆ្នាំ២០២០ ខាងក្រុមហ៊ុន បានយកខ្លួនទៅលក់ឱ្យក្រុមហ៊ុន ជឹងឆាយ៥ ដោយនៅពេលនោះមានជនជាតិចិន ០៣នាក់ ភេទប្រុស ១-ឈ្មោះ [redacted] XIANG PING និង០២នាក់ទៀតមិនស្គាល់ឈ្មោះ បានជិះរថយន្ត ០១គ្រឿងម៉ាក ស្តារិច ពណ៌ខ្មៅ (មិនចាំស្លាកលេខ) មកដឹកខ្លួនចេញពីក្រុមហ៊ុន ខាយប៉ ទៅក្រុមហ៊ុន ជឹងឆាយ៥ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុង-ខេត្តព្រះសីហនុ លុះបាន ០៣ថ្ងៃក្រោយមកទើបក្រុមហ៊ុន ខាយប៉ បានលក់ប្ដីរបស់ខ្លួនមក ក្រុមហ៊ុន ជឹងឆាយ៥ ធ្វើការជាមួយខ្លួនដែរ។ ពេលទៅដល់ក្នុងអាគារជឹងឆាយ៥ ខាងក្រុមហ៊ុនបានយកពួកខ្លួនទៅជាន់ទី១ (មិនចាំលេខបន្ទប់ រួចបានអោយពួកខ្លួនធ្វើការងារផ្នែកកំព្យូទ័រអនឡាញ នៅអាគារទី១០ ជាន់ទី៧ លេខបន្ទប់៧០១ ហើយខាងក្រុមហ៊ុនបានឱ្យខ្លួនស្នាក់នៅជាន់ទី៥ បន្ទប់លេខ ៥១៣ រីឯប្ដីរបស់ខ្លួនស្នាក់នៅបន្ទប់លេខ៥១៨ ហើយក្នុងមួយថ្ងៃពួកខ្លួនធ្វើការរយៈពេល ១២ម៉ោង ក្រុមហ៊ុនមិនបានអោយប្រាក់ខែពួកខ្លួនទេ ធ្វើការនៅទីនោះបានរយៈពេល ០៣ខែ ពួកខ្លួនក៏បានសុំក្រុមហ៊ុនជឹងឆាយ៥ ឈប់ពីការងារ ពេលនោះខាងក្រុមហ៊ុនបាននិយាយថាបើចង់ឈប់ពួកខ្លួនទាំងពីរនាក់ប្ដីប្រពន្ធត្រូវសងលុយក្រុមហ៊ុនចំនួន USD ៧០,០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ទើបអោយពួកខ្លួនឈប់ពីក្រុមហ៊ុនបាន បន្ទាប់មកខាងក្រុមហ៊ុន បានឱ្យឈ្មោះ [redacted] XIANG PING និងឈ្មោះ [redacted] XIANG QUAN មកយកប្ដីរបស់ខ្លួនឡើងទៅជាន់ទី៥ រួចទើបមកយកខ្លួនឡើងទៅជាន់ទី៥តាមក្រោយ ហើយពួកវាទាំងពីរនាក់បានឃុំខ្លួននៅបន្ទប់លេខ៥២៧ បន្ទាប់មកឈ្មោះ [redacted] XIANG PING បានយកខ្នោះដៃមកដាក់ខ្លួនជាប់ជាមួយជើងគ្រែរួចបានប្រើដៃទះក្បាលរបស់ខ្លួន ០១ដៃ ទះកំភ្លៀងខ្លួន ០១កំភ្លៀង និងយកស្បែកជើងមកវាយក្បាលខ្លួនជាច្រើនលើក ចំណែកប្ដីរបស់ខ្លួនត្រូវបានពួកវាយកឃុំទុកនៅបន្ទប់លេខ៥០២ ហើយក៏ត្រូវពួកវាដាក់ខ្នោះដៃវាយជាប់គ្រែដូចខ្លួនដែរ ពួកវាបានឃុំខ្លួន និងប្ដីរបស់ខ្លួនក្នុងបន្ទប់ផ្សេងពីគ្នាអស់រយៈពេល ០១សប្តាហ៍ទើបយកពួកខ្លួនមកឃុំជាមួយគ្នារយៈពេល ០១សប្តាហ៍ទៀត រួចបានឱ្យពួកខ្លួនចុះកុងត្រាជាមួយក្រុមហ៊ុនត្រូវធ្វើការឱ្យក្រុមហ៊ុនរយៈពេល ០២ឆ្នាំ។ បានរយៈពេល ០២ថ្ងៃក្រោយគឺនៅថ្ងៃទី២៨

ខែសីហា ឆ្នាំ២០២២ ខាងក្រុមហ៊ុន ជឹងឆាយ៥ បានយកពួកខ្លួនទាំង ០២នាក់ចូលក្នុងរថយន្ត ០១គ្រឿង ម៉ាក ស្តារិច ពណ៌ខ្មៅ (មិនចាំស្លាកលេខ) ហើយខាងក្រុមហ៊ុនមានគ្នា០៣នាក់រួមមាន៖ ១-ឈ្មោះ [redacted] QIAO LONG (ជាប្អូនថៅកែ) និង០២នាក់ទៀត (មិនស្គាល់ឈ្មោះ) បានដឹកពួកខ្លួនទៅលក់ឱ្យក្រុមហ៊ុន ជាវសានទីង ពេលទៅដល់ថ្ងៃទី០១ ខាងក្រុមហ៊ុនបានយកពួកខ្លួនទៅស្នាក់នៅជាន់ទី២ (មិនចាំលេខបន្ទប់) លុះនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ពេលយប់មិនចាំម៉ោងខាងក្រុមហ៊ុន ជាវសានទីង បានឱ្យបុរសជនជាតិចិនម្នាក់ឈ្មោះ [redacted] LIN JIAN ដឹកពួកខ្លួនមកក្រុមហ៊ុន ជឹងឆាយ៥ វិញ ពេលមកដល់ក៏មានសមត្ថកិច្ចចាំនៅទីនោះហើយ សមត្ថកិច្ចបានជួយរំដោះពួកខ្លួនទាំង ០២នាក់ប្តី-ប្រពន្ធ និងបានឃាត់ខ្លួនឈ្មោះ [redacted] LIN JIAN តែម្តង។ ខ្លួន និងប្តីរបស់ខ្លួនបានទាក់ទងទៅគ្រួសារដែលនៅប្រទេសចិន ដើម្បីអោយពួកគាត់ជួយប្តឹងសមត្ថកិច្ចមកជួយរំដោះពួកខ្លួនចេញពីក្រុមហ៊ុនក្នុងពេលដែលពួកខ្លួនត្រូវបានគេលក់ទៅឱ្យក្រុមហ៊ុន ជឹងឆាយ៥។ ចំពោះឈ្មោះ [redacted] JIE ភេទស្រី និងឈ្មោះ [redacted] YU ភេទស្រី ពួកខ្លួនស្នាក់នៅបន្ទប់ជាមួយគ្នាហើយពួកខ្លួនមានការឈ្លោះប្រកែកគ្នាក៏មានការប្រើហិង្សាបន្តិចបន្តួចពេលនៅក្នុងបន្ទប់ស្នាក់នៅ ពួកគាត់ទាំង០២នាក់មិនជាប់ពាក់ព័ន្ធនឹង ករណីចាប់បង្ខាំងវាយធ្វើបាបពួកខ្លួនទេ។

-អំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] YONG GUI នៅជំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ បានឱ្យដឹងថា៖ កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ ខ្លួនបានមកដល់ប្រទេសកម្ពុជាដោយជិះយន្តហោះពីខេត្តគ័ងចូវ ប្រទេសចិន មកចុះនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ និងបានបន្តដំណើរមកខេត្តព្រះសីហនុ ដើម្បីទេសចរណ៍។ នៅក្នុងអំឡុងខែមេសា ឆ្នាំ២០២២ ខ្លួន និងប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] JIA XU ជនជាតិចិន បានស្នាក់នៅក្នុងសណ្ឋាគារ វិមានខ្សាច់ស នៅពាក់កណ្តាលយប់មិនចាំម៉ោងគឺខ្លួន និងប្រពន្ធរបស់ខ្លួន បានដើរចេញពីសណ្ឋាគារទៅហូបបាយនៅឆ្នេរសមុទ្រអូរឈើទាលដែលនៅទល់មុខសណ្ឋាគារ ពេលដើរតាមផ្លូវ ក៏ស្រាប់តែមានរថយន្ត ០១គ្រឿង ម៉ាក ស្តារិច ពណ៌ខ្មៅ (មិនចាំស្លាកលេខ) បានជិះមកពីក្រោយពួកខ្លួន ហើយក៏មានជនជាតិចិន ០៣នាក់បានចុះមកពីរថយន្តស្ទុះមកចាប់ប្រពន្ធរបស់ខ្លួនឡើងរថយន្តពេលនោះខ្លួន បានស្ទុះមកជួយប្រពន្ធរបស់ខ្លួន ស្រាប់តែត្រូវពួកវាចាប់ខ្លួន និងប្រពន្ធរបស់ខ្លួនឡើងរថយន្តទាំងអស់គ្នា តែម្តង នៅក្នុងរថយន្ត នោះពួកវាមានគ្នា ០៥នាក់ ជាជនជាតិចិនទាំងអស់ពេលដែលពួកវាចាប់ពួកខ្លួនឡើង រថយន្ត ពួកវាបានវាយពួកខ្លួននៅក្នុងរថយន្ត ហើយពួកវាបានដកយកទូរស័ព្ទដៃរបស់ពួកខ្លួន រួចបានដឹកពួកខ្លួន យកទៅក្រុមហ៊ុន ឆាយណាថោន ហើយពួកវាបានឃុំពួកខ្លួនទាំងពីរនាក់នៅក្នុងអគារ ខាយប៉ មិនចាំលេខ អគារ បន្ទប់លេខ ៣០៣ ដើម្បីបង្ខំឱ្យពួកខ្លួនធ្វើការងារអនឡាញនៅទីនោះ។ រំលងបានរយៈពេល០២ថ្ងៃ ខាងក្រុមហ៊ុនបានឱ្យពួកខ្លួនចាប់ផ្តើមធ្វើការងារផ្នែកកំព្យូទ័រនៅអាគារទី៥ ជាន់ទី១, បន្ទប់លេខ១០៣ តែខាង ក្រុមហ៊ុនមិនបានឱ្យ ប្រាក់ខែពួកខ្លួនទេ។ ហើយនៅពេលដែលពួកខ្លួនមិនព្រមធ្វើការងារឱ្យក្រុមហ៊ុនក៏មាន ជនជាតិចិន៣នាក់ ១-ឈ្មោះ [redacted] BING LONG ភេទប្រុស ជាអ្នកគ្រប់គ្រង,២-ឈ្មោះ [redacted] JIE ភេទស្រី, ៣-ឈ្មោះ [redacted] YU ភេទស្រី បានវាយធ្វើបាបពួកខ្លួនដោយប្រើដៃ-ជើង និងបានយកដំបងឆក់ មកឆក់ខ្លួន ពួកវាបានវាយប្រពន្ធរបស់ខ្លួនឡើងហើមមុខហើមមាត់ ហើយបានគំរាមពួកខ្លួនថា បើពួកខ្លួនមិនធ្វើការឱ្យ ក្រុមហ៊ុនទេ ពួកវា នឹងវាយធ្វើបាបពួកខ្លួនទៀត បន្ទាប់មកពួកវាបានវាយពួកខ្លួនទៅឃុំទុកនៅបន្ទប់ផ្សេងពីគ្នា ហើយពួកវាបាន ឱ្យបក្ខពួករបស់ពួកវា ០២នាក់ ម្នាក់ជាជនជាតិចិន ភេទប្រុស និងម្នាក់ទៀតជាជនជាតិ ម៉ាឡេស៊ី យកខ្នោះដៃ មកដាក់ពួកខ្លួនជាប់នៅគ្រែដេក ដោយពួកខ្លួនមិនអាចធ្វើអ្វីបានទើបបង្ខំចិត្តព្រមធ្វើការ ឱ្យពួកវា។ នៅអំឡុងខែមិថុនា ឆ្នាំ២០២២ ខាងក្រុមហ៊ុនបានយកប្រពន្ធរបស់ខ្លួនទៅលក់ឱ្យក្រុមហ៊ុន ជឹងឆាយ៥៚

លុះបាន ០៣ថ្ងៃក្រោយមកទើបក្រុមហ៊ុន ខាយប៉ បានលក់ខ្លួនទៅឱ្យក្រុមហ៊ុន ជឹងឆាយ៥ ដែរដោយនៅពេលនោះមានជនជាតិចិន ០៣នាក់ ភេទប្រុស ១-ឈ្មោះ [redacted] XIANG PING និងពីរនាក់ទៀតមិនស្គាល់ឈ្មោះបានជិះរថយន្ត ០១គ្រឿង ម៉ាក ស្តារិច ពណ៌ខ្មៅ (មិនចាំស្លាកលេខ) មកយកខ្លួនចេញពីក្រុមហ៊ុន ខាយប៉ ទៅក្រុមហ៊ុន ជឹងឆាយ៥ ហើយខ្លួនបានឃើញឈ្មោះ [redacted] XIANG PING ប្រគល់លុយទៅឱ្យឈ្មោះ [redacted] BING LONG ចំនួន USD ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក។ ពេលទៅដល់ក្នុងអាគារជឹងឆាយ៥ ខាងក្រុមហ៊ុនបានឱ្យខ្លួនចូលធ្វើការ ជាមួយប្រពន្ធរបស់ខ្លួននៅជាន់ទី១ (មិនចាំលេខបន្ទប់) រួចបានអោយពួកខ្លួនធ្វើការងារផ្នែកកំព្យូទ័រអេនឡាញ នៅអាគារទី១០ ជាន់ទី៧ លេខបន្ទប់ ៧០១ ហើយខាងក្រុមហ៊ុនបានឱ្យប្រពន្ធរបស់ខ្លួនស្នាក់នៅជាន់ទី៥ បន្ទប់លេខ ៥១៣ រីឯខ្លួនស្នាក់នៅបន្ទប់លេខ៥១៨ ក្នុងមួយថ្ងៃពួកខ្លួនធ្វើការ ១២ម៉ោងក្រុមហ៊ុនមិនបានឱ្យប្រាក់ខែពួកខ្លួនទេធ្វើការនៅទីនោះបានរយៈពេល ០៣ខែ នៅតែមិនបើកប្រាក់ខែឱ្យពួកខ្លួនទៀត ទើបពួកខ្លួនក៏បានសុំឈ្មោះ [redacted] QIAO LONG (ជាអ្នកគ្រប់គ្រង) ឈប់ពីការងារ។ ពេលនោះ ឈ្មោះ [redacted] QIAO LONG ជាអ្នកគ្រប់គ្រង បាននិយាយថាបើចង់ឈប់ពួកខ្លួនទាំងពីរនាក់ ប្តី-ប្រពន្ធ ត្រូវសងលុយមកឱ្យក្រុមហ៊ុនចំនួន USD ៧០,០០០(ប្រាំពីរម៉ឺន) ដុល្លាអាមេរិក ទើបអោយពួកខ្លួនឈប់ពីក្រុមហ៊ុនបាន បន្ទាប់មកឈ្មោះ [redacted] XIANG PING បានទះខ្លួនចំនួន ០១កំភ្លៀង ហើយឈ្មោះ [redacted] QIAO LONG (ជាអ្នកគ្រប់គ្រង) បានឱ្យឈ្មោះ [redacted] XIANG PING និងឈ្មោះ [redacted] QUAN មកយកខ្លួនឡើងទៅជាន់ទី៥ រួចឃុំខ្លួនទុកនៅបន្ទប់លេខ: ៥០២ ហើយឈ្មោះ [redacted] QUAN បានយកខ្នោះដៃមកដាក់ខ្លួនជាប់ជាមួយជើងគ្រែ ចំណែកឯប្រពន្ធរបស់ខ្លួន ត្រូវបានពួកវាយកទៅឃុំទុកនៅបន្ទប់លេខ៥២៧ ជាន់ទី៥ ហើយត្រូវបានពួកវាដាក់ខ្នោះដៃជាប់ជាមួយជើងគ្រែដូចខ្លួនដែរ ពួកវាបានប្រើហិង្សាលើប្រពន្ធរបស់ខ្លួនដោយប្រើដៃទះក្បាល ទះកំភ្លៀង និងយកស្បែកជើងទៅវាយក្បាលប្រពន្ធរបស់ខ្លួន ពួកវាបានឃុំពួកខ្លួនក្នុងបន្ទប់ផ្សេងពីគ្នាអស់រយៈពេល ០១សប្តាហ៍ ទើបយកពួកខ្លួនមកឃុំក្នុងបន្ទប់ជាមួយគ្នារយៈពេល ០១សប្តាហ៍ទៀត រួចបានឱ្យពួកខ្លួនចុះកុងត្រាជាមួយក្រុមហ៊ុនត្រូវធ្វើការឱ្យក្រុមហ៊ុនរយៈពេល ០២ឆ្នាំ បានរយៈពេល ០២ថ្ងៃក្រោយ គឺនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២២ ខាងក្រុមហ៊ុនជឹងឆាយ៥ បានយកពួកខ្លួនទាំង ០២នាក់ ចូលក្នុងរថយន្ត ០១ គ្រឿង ម៉ាក់ស្តារិច ពណ៌ខ្មៅ (មិនចាំស្លាកលេខ) ហើយខាងក្រុមហ៊ុនមានគ្នា០៣នាក់រួមមាន៖ ១-ឈ្មោះ [redacted] QIAO LONG (ជាប្អូនរបស់ថៅកែ) និងពីរនាក់ទៀតមិនស្គាល់ឈ្មោះ បានដឹកពួកខ្លួនទៅលក់ឱ្យក្រុមហ៊ុន ជាវសានទីង ពេលទៅដល់ក្រុមហ៊ុនជាវសានេទីង ខាងក្រុមហ៊ុនបានយកពួកខ្លួនទៅស្នាក់នៅជាន់ទី២ (មិនចាំលេខបន្ទប់) លុះនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ពេលយប់មិនចាំម៉ោងខាងក្រុមហ៊ុន ជាវសានទីង បានឱ្យបុរសជនជាតិចិនម្នាក់ឈ្មោះ [redacted] LIN JIAN ដឹកពួកខ្លួនមកក្រុមហ៊ុន ជឹងឆាយ៥ វិញ ពេលមកដល់ក៏មានសមត្ថកិច្ចចាំនៅទីនោះ ហើយសមត្ថកិច្ច បានជួយរំដោះពួកខ្លួនទាំងពីរនាក់ប្តីប្រពន្ធ និងបានឃាត់ខ្លួនឈ្មោះ [redacted] LIN JIAN តែម្តង។ ពេលដែលខាងក្រុមហ៊ុន ជឹងឆាយ៥ លក់ពួកខ្លួនទាំងពីរនាក់ប្តី ប្រពន្ធ ទៅអោយក្រុមហ៊ុន ជាវសានទីង ពួកខ្លួនមិនដឹងថាខាងក្រុមហ៊ុនលក់ពួកខ្លួនក្នុងតំលៃប៉ុន្មាននោះទេហើយខាងក្រុមហ៊ុន ខាយប៉ ដែលលក់ពួកខ្លួនទៅអោយក្រុមហ៊ុនក៏ខ្លួនមិនបានដឹងថាក្រុមហ៊ុនលក់ពួកខ្លួនក្នុងតំលៃប៉ុន្មានដែរ។ ខ្លួន និងប្រពន្ធរបស់ខ្លួន បានទាក់ទងទៅគ្រួសារដែលនៅប្រទេសចិន ដើម្បីឱ្យជួយប្តឹងសមត្ថកិច្ចមកជួយរំដោះពួកខ្លួនចេញពីក្រុមហ៊ុន ក្នុងពេលដែលពួកខ្លួន ត្រូវបានគេលក់ទៅឱ្យក្រុមហ៊ុន ជឹងឆាយ៥ ខ្លួន និងប្រពន្ធរបស់ខ្លួន បានចុះកុងត្រាការងាររយៈពេល ០២ឆ្នាំជាមួយក្រុមហ៊ុន ជឹងឆាយ៥ ពិតមែន តែដោយសារការបង្ខិតបង្ខំពីក្រុមហ៊ុនទើបពួកខ្លួនចុះកុងត្រា។

-អំណាចចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] YAN នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌បានឱ្យដឹងថា៖ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៨ ខ្លួនបានជិះយន្តហោះមកពីសិនជិន ប្រទេសចិន ចុះនៅព្រលានយន្តហោះអន្តជាតិភ្នំពេញ ប្រទេសកម្ពុជា មកដើម្បីទេសចរណ៍។ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ខ្លួនបានទៅហូបបាយនៅផ្ទះម៉ូអូរឈើទាល ពេលនោះក៏បានអង្គុយរួមតុជាមួយជនជាតិចិន ០១នាក់ ភេទប្រុស មិនស្គាល់ឈ្មោះ និងមិនធ្លាប់ស្គាល់ពីមុនទេ ពេលនោះពួកខ្លួនក៏អង្គុយនិយាយគ្នាលេងនៅតុបាយ ខ្លួនក៏បានសួរទៅគាត់ថាមានការងារធ្វើទេខ្លួនចង់រកការងារធ្វើ ពេលនោះគាត់ប្រាប់ថាបើចង់ធ្វើការងារគាត់យកទៅធ្វើការងារជាមួយពួកម៉ាករបស់គាត់នៅម៉ុំឆាយណាថោន ពេលនោះខ្លួនក៏យល់ព្រមទៅជាមួយគាត់ភ្លាមតែម្តងពេលទៅដល់ទីនោះគាត់បានយកខ្លួនចូលទៅ ក្នុងក្រុមហ៊ុន ខាយប៉ ការងារនៅអាគារទី៥ ជាន់ទី២ បន្ទប់លេខ ១០៣ និងបន្ទប់ស្នាក់នៅជាន់ទី៧ បន្ទប់លេខ៧១២ ជាបុគ្គលិកកុំព្យូទ័រទទួលបានប្រាក់ខែ USD ១,០០០ (មួយពាន់) ដុល្លាអាមេរិក ហើយអ្នកគ្រប់គ្រងខ្លួន នៅអាគារដែលខ្លួនធ្វើការមានឈ្មោះ [redacted] BING LONG ជាជនជាតិចិន ភេទប្រុស តែពេលដែលខ្លួនចូលធ្វើការងារខ្លួនមិនបានធ្វើកិច្ចសន្យាកុងត្រាជាមួយក្រុមហ៊ុនទេ ខ្លួនធ្វើការបានរយៈពេល ០៣ថ្ងៃ ខ្លួនក៏បានសុំអ្នកគ្រប់គ្រងឈ្មោះ [redacted] BING LONG ជាជនជាតិចិនឈប់ធ្វើការ ព្រោះការងារដែលខ្លួនមកធ្វើនេះគឺជាការងារខុសច្បាប់ (ល្បែងអនឡាញ) តែពេលនោះគាត់បាននិយាយថា បើសិនជាខ្លួនចង់ឈប់ ខ្លួនត្រូវសងលុយអោយក្រុមហ៊ុនវិញចំនួន USD ២៦,០០០ (ពីរម៉ឺនប្រាំមួយពាន់) ដុល្លាអាមេរិក ព្រោះខាងក្រុមហ៊ុនទិញខ្លួនមកចូលធ្វើការ ពេលនោះទើបខ្លួនបានដឹងថាបុរសជនជាតិចិនម្នាក់នោះបានយកខ្លួនមកលក់ឱ្យក្រុមហ៊ុន ដើម្បីធ្វើការអនឡាញ ពេលនោះខ្លួនមិនមានលុយអោយទៅក្រុមហ៊ុនទេខាងក្រុមហ៊ុនក៏បានអោយខ្លួនធ្វើការងាររហូតដោយមិនបានបើកប្រាក់ខែអោយខ្លួនទេអោយតែកន្លែងស្នាក់នៅ និងហូបចុកតែប៉ុណ្ណោះ ខាងក្រុមហ៊ុនមិនបានវាយ ធ្វើបាបខ្លួនទេ ពេលខ្លួនឈឺអាចសុំច្បាប់ឈប់សំរាកបានតែអនុញ្ញាតអោយខ្លួនដើរបានតែក្នុងបរិវេណអាគារប៉ុណ្ណោះ ក្រុមហ៊ុនមិនឱ្យប្រើទូរស័ព្ទនៅក្នុងម៉ោងការងារទេចប់ម៉ោងការងារទើបអោយប្រើក្នុង ០១ថ្ងៃខាងក្រុមហ៊ុនអោយធ្វើការងាររយៈពេល ១២ម៉ោង។ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ១៦៖០០នាទី មានសមត្ថកិច្ចមកដល់ក្រុមហ៊ុនដើម្បីដើម្បីស្វែងរកមនុស្សពេលនោះខ្លួនក៏បានប្រាប់ទៅសមត្ថកិច្ចអោយជួយ យកខ្លួនចេញពីក្រុមហ៊ុនព្រោះខ្លួនធ្វើការងារនៅក្នុងក្រុមហ៊ុននេះ មានសម្ពាធណាស់ ធ្វើការងារច្រើនម៉ោងមិនមានប្រាក់ខែបើក ហើយខ្លួនត្រូវបានគេបោកបញ្ឆោតយកមកលក់ឱ្យក្រុមហ៊ុនដោយមិនបានដឹងខ្លួន ពេលនោះសមត្ថកិច្ចក៏បានជួយរំដោះខ្លួនចេញពីក្រុមហ៊ុនតែម្តង។ ក្នុងអំឡុងពេលដែលខ្លួនធ្វើការនៅក្នុងបន្ទប់ដែលខ្លួន ស្នាក់នៅមានគ្នា ០៤នាក់រួមមាន៖ ១-ខ្លួន, ២-ឈ្មោះ [redacted] JIA XU, ៣-ឈ្មោះ [redacted] JEI, និង៤-ឈ្មោះ [redacted] YU ពួកខ្លួនទាំងបួននាក់ស្នាក់នៅក្នុងបន្ទប់លេខ៧១២ ជាន់ទី៧ ជាមួយគ្នាហើយនៅថ្ងៃមួយខ្លួនបានឃើញ ឈ្មោះ [redacted] JEI និងឈ្មោះ [redacted] YU បានវាយទៅលើឈ្មោះ [redacted] JIA XU។

- ជនជាប់ចោទឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN បានឆ្លើយថា៖ ខ្លួនស្គាល់ជនរងគ្រោះ ព្រោះជនរងគ្រោះធ្លាប់ធ្វើការនៅក្រុមហ៊ុនរបស់ខ្លួន។ នៅក្នុងក្រុមហ៊ុន ខ្លួនធ្វើការផ្នែកគ្រប់គ្រង ប៉ុន្តែគ្រប់គ្រងខាងផ្នែកហូបចុកប្រចាំថ្ងៃ។ ខ្លួនស្គាល់ជនរងគ្រោះទាំងពីរនាក់ប្តីប្រពន្ធក្នុងអំឡុងខែឧសភា។ ខ្លួនមិនមានទំនាក់ទំនងការងារជាមួយពួកគេទេ។ ខ្លួនមិនបានបង្ខាំងជនរងគ្រោះឱ្យធ្វើការឱ្យក្រុមហ៊ុនរបស់ខ្លួនទេ រឿងក្រុមហ៊ុនបង្ខាំងមនុស្សខ្លួនមិនបានដឹងទេ ក្រុមហ៊ុនជាអ្នករៀបចំ។ ហើយខ្លួន ក៏មិនបានដឹងថាក្រុមហ៊ុនធ្វើការបង្ខាំងមនុស្សដែរ។ មូលហេតុដែលជនរងគ្រោះឆ្លើយថាខ្លួនជាអ្នកបង្ខាំងពួកគេ ព្រោះតែពេលដែលពួកគេចូលមកធ្វើការខ្លួន

ជាអ្នករៀបចំកន្លែងស្នាក់នៅឱ្យពួកគេ ដូច្នេះពួកគេកេអ្នកដែលបង្ខាំងពួកគេមិនឃើញ និងមិនដឹងឆ្លើយដាក់អ្នកណា ក៏ឆ្លើយដាក់ខ្លួនតែម្តង។ ខ្លួនមិនបាននៅយាមជនរងគ្រោះទេ។ ខ្លួនមិនបានបង្ខាំងមនុស្សទេ ហើយខ្លួនក៏មិនធ្លាប់បានទទួលប្រាក់ពីឈ្មោះ [redacted] XIANG PING ដែរ។ អ្នកដែលឃាត់ខ្លួនមកជាមួយ ខ្លួនមិនស្គាល់អ្នកណាម្នាក់ទេ។ មូលហេតុដែលជនរងគ្រោះធ្វើការនៅក្រុមហ៊ុនរបស់ខ្លួនសុខៗ ក៏ប្តូរទៅក្រុមហ៊ុនផ្សេង ព្រោះក្រុមហ៊ុន រកឃើញថាទាំងពីរនាក់ប្តីប្រពន្ធប្រើប្រាស់គ្រឿងញៀន ក្រុមហ៊ុនក៏ឈប់ឱ្យពួកគេធ្វើការ។ ពេលដែលឈប់ឱ្យជនរងគ្រោះធ្វើការ ក្រុមហ៊ុន បានធ្វើលិខិតបញ្ឈប់ឱ្យធ្វើការដែរ ប៉ុន្តែមិនបានដាក់ភស្តុតាងមកតុលាការទេ។ អំឡុងពេលដែលជនរងគ្រោះនៅក្រុមហ៊ុនរបស់ខ្លួន ខ្លួនមិនបានវាយទៅលើជនរងគ្រោះ ឬបញ្ជាឱ្យគេវាយទៅលើជនរងគ្រោះទេ ហើយក៏មិនបានប្រើដំបងឆក់ដែរ។ នៅក្នុងក្រុមហ៊ុនរបស់ខ្លួនមិនមានដំបងឆក់ទេ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] JIE ទេ ប៉ុន្តែឈ្មោះ [redacted] YU ភេទស្រី ខ្លួនស្គាល់។ ពេលដែលជនរងគ្រោះធ្វើការនៅក្រុមហ៊ុនរបស់ខ្លួន ជនរងគ្រោះមិនមានរបួសអ្វីទេ។ ក្រុមហ៊ុនបញ្ឈប់ជនរងគ្រោះប្រហែលជាចុងខែឧសភា។ ជនរងគ្រោះធ្វើការនៅក្រុមហ៊ុនបានជិត ០១(មួយ)ខែ។ នៅពេលដែលក្រុមហ៊ុនបញ្ឈប់ជនរងគ្រោះមិនឱ្យធ្វើការជនរងគ្រោះបានទាក់ទងទៅមិត្តភក្តិរបស់ជនរងគ្រោះឱ្យមកទទួលដោយខ្លួនឯង មិនមែនក្រុមហ៊ុនជាអ្នករៀបចំឱ្យទេ ខ្លួនមិនស្គាល់អ្នកដែលមកទទួលជនរងគ្រោះនោះទេ។ ខ្លួនមិនបានឃើញជនរងគ្រោះចេញទៅជាមួយគេទេ។ ខ្លួនដឹងថាជនរងគ្រោះឱ្យមិត្តភក្តិមកទទួល ព្រោះអ្នកធ្វើការនៅក្រុមហ៊ុនបានប្រាប់ខ្លួនថាជនរងគ្រោះបានប្រើប្រាស់គ្រឿងញៀន និងត្រូវបានក្រុមហ៊ុនបញ្ឈប់ ហើយជនរងគ្រោះបានទាក់ទងឱ្យគេមកទទួលចេញទៅបាត់ហើយ។ ខ្លួនជាអ្នកគ្រប់គ្រងផ្នែកទិញឥវ៉ាន់ប្រើប្រាស់ប្រចាំថ្ងៃ បុគ្គលិកដែលធ្វើការនៅក្នុងក្រុមហ៊ុន គឺខាងក្រុមហ៊ុនជាអ្នកបើកប្រាក់ខែឱ្យ អ្នកដែលបើកប្រាក់ខែឱ្យបុគ្គលិកមានឈ្មោះថា [redacted] QIANG។ ឈ្មោះ [redacted] QIANG មិនបានឃាត់ខ្លួនមកជាមួយទេ។ ចំពោះមនុស្សចេញចូលគឺឈ្មោះ [redacted] QIANG ដឹង។ ខ្លួនធ្វើការខាងទិញសម្ភារៈដូចជា៖ ភួយ, ខ្នើយ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ ដែលក្រុមហ៊ុនត្រូវការចាំបាច់ប្រចាំថ្ងៃ។ នៅក្នុងក្រុមហ៊ុនមានមនុស្សប្រហែល០៨នាក់ គិតទាំងជនរងគ្រោះ។ ជនរងគ្រោះទាំងពីរនាក់ធ្វើការផ្នែកវាយកំព្យូទ័រ។ ជនរងគ្រោះប្តឹងថាខ្លួនបង្ខាំងមនុស្សព្រោះជនរងគ្រោះ ខឹងក្រុមហ៊ុន បញ្ឈប់ពីការងារ។ ជនជាប់ចោទ ០៤(បួន)នាក់ទៀត ខ្លួនមិនដែលឃើញនៅក្រុមហ៊ុនរបស់ខ្លួនទេ។ ខ្លួនក៏មិនដឹងដែលថាហេតុអ្វីបានជា ០៤នាក់នោះត្រូវគេប្តឹងដែរទេ។ ខ្លួនទើបតែមកប្រទេសកម្ពុជា ក្នុងខែមេសា។ ខ្លួនមិនបានគម្រាមជនរងគ្រោះថា បើជនរងគ្រោះមិនព្រមធ្វើការ ខ្លួននឹងឱ្យជនងគ្រោះទៅធ្វើការនៅកន្លែងផ្សេងទេ។ ខ្លួនជាប់ឃុំឃាំងក្នុងពន្ធនាគាររយៈពេល ០៧(ប្រាំពីរ)ខែហើយ។ បន្ទាប់ពីក្រុមហ៊ុនបញ្ឈប់ជនរងគ្រោះមិនឱ្យធ្វើការ ជនរងគ្រោះបានទាក់ទងឱ្យគេមកទទួលចេញទៅ ជនរងគ្រោះជាអ្នកទាក់ទងទៅដោយខ្លួនឯង។ ក្រុមហ៊ុនឱ្យជនរងគ្រោះចេញទៅដោយសន្តិវិធី។ ក្នុងក្រុមហ៊ុនរបស់ខ្លួនពេលដែលមានបុគ្គលិកមកធ្វើការ គឺបុគ្គលិកត្រូវចុះកុងត្រាជាមួយក្រុមហ៊ុនរយៈពេលមួយឆ្នាំ។ ខ្លួនមិនបានលក់ជនរងគ្រោះឱ្យទៅក្រុមហ៊ុន ដឹងឆាយ៥ ទេ។ ក្រុមហ៊ុន ខាយប៉ ជាអគារដែលមានរបងព័ទ្ធជុំវិញ ប្រសិនបើចង់ចេញទៅខាងក្រៅគឺត្រូវចេញតាមមាត់ទ្វារចូល បុគ្គលិកមានសិទ្ធិអាចចេញចូលបាន ប៉ុន្តែត្រូវប្រាប់អ្នកយាមដែលយាមនៅច្រកចេញចូល ហើយបុគ្គលិកមានសិទ្ធិចេញចូលបានគ្រប់គ្នា។ ខ្លួនស្គាល់ឈ្មោះ [redacted] QIANG ប៉ុន្តែមិនស្គាល់ត្រកូលទេ។ ចំពោះឈ្មោះ [redacted] PING ខ្លួនមិនស្គាល់ទេ។ ខ្លួនមិនបានទទួលលុយពីឈ្មោះ [redacted] XIANG PING ទេ។ ខ្លួនមិនបានលក់ដូរមនុស្សចេញទៅទេ។ ខ្លួនមានអ្នកគ្រប់គ្រងលើខ្លួនម្នាក់ទៀតគឺឈ្មោះ [redacted] QIANG ខ្លួនមិនដឹងថាអ្នកណាជាថ្នាក់លើរបស់ឈ្មោះ [redacted] QIANG ទេ ព្រោះខ្លួនទើបតែចូលធ្វើការ។ ពេលដែលជនរងគ្រោះចូលធ្វើការ/.

ប្រហែលជាជនរងគ្រោះទាក់ទងមកក្រុមហ៊ុនផ្ទាល់ ព្រោះជនរងគ្រោះមិនបានទាក់ទងមកខ្លួនទេ។ ការងារដែលបុគ្គលិកត្រូវធ្វើនៅក្រុមហ៊ុន ខាយប៉ គឺឈ្មោះ [redacted] QIANG ជាអ្នកបញ្ជា និងជាអ្នកបើកប្រាក់ខែឱ្យ។ ពេលដែលជនរងគ្រោះមកធ្វើការខ្លួនជាអ្នកនាំជនរងគ្រោះទៅកន្លែងស្នាក់នៅ។ ជនរងគ្រោះមិនមែនជាប្ដីប្រពន្ធនឹងគ្នាទេ គ្រាន់តែជាមិត្តប្រុស និងមិត្តស្រី។ មូលហេតុដែលខ្លួនបំបែកឱ្យជនរងគ្រោះស្នាក់នៅផ្សេងគ្នាព្រោះ ក្រុមហ៊ុនមានគោលការណ៍ឱ្យបុគ្គលិកស្រី ស្នាក់នៅមួយឡែក និងបុគ្គលិកប្រុសស្នាក់នៅមួយឡែក។ ក្រុមហ៊ុនធ្លាប់ឱ្យជនរងគ្រោះខ្ចីលុយ USD ៧០០ (ប្រាំពីរយ)ដុល្លារអាមេរិក ជនរងគ្រោះធ្វើការបានប្រាក់ខែម្នាក់ USD ១,០០០ (មួយពាន់)ដុល្លារអាមេរិក ក្នុងមួយខែ។ ចំពោះដំបងឆក់ និងខ្នោះដៃ ០២គូ គឺធែកឃើញនៅក្រុមហ៊ុនផ្សេងមិនស្គាល់ឈ្មោះ ជាប់ក្រុមហ៊ុនរបស់ខ្លួន មិនមែនធែកឃើញនៅក្នុងក្រុមហ៊ុនរបស់ខ្លួនទេ។ ជនរងគ្រោះចេញពីក្រុមហ៊ុន អំឡុងខែមិថុនា ឆ្នាំ២០២២។ ក្នុងខែមេសា ខ្លួនទើបមកដល់ប្រទេសកម្ពុជា ចំណែកជនរងគ្រោះជាប្រពន្ធចូលធ្វើការនៅចុងខែមេសា និងជនរងគ្រោះជាប្ដីចូលធ្វើការក្នុងខែឧសភា។ ខ្លួនមិនមានរថយន្តផ្ទាល់ខ្លួនទេ។ អំឡុងខែមេសា ខ្លួនស្នាក់នៅក្នុងក្រុមហ៊ុន ខ្លួនមិនបានជិះឡានទៅម្ដុំខ្សាច់សទេ។ ខ្លួនមិនបានចាប់ជនរងគ្រោះចូលក្នុងឡានទេ។ ពេលដែលជនរងគ្រោះមកធ្វើការមិនមាននរណាចាប់ជនរងគ្រោះមកទេ គឺជនរងគ្រោះមកដោយខ្លួនឯង។ ក្រុមហ៊ុនមានឱ្យបុគ្គលិកផ្សេងៗខ្ចីប្រាក់ដែរ ប៉ុន្តែឱ្យខ្ចីត្រឹមតែ USD ៧០០ (ប្រាំពីរយ)ដុល្លារអាមេរិក តែប៉ុណ្ណោះ លើសពីនេះខ្លួនមិនបានដឹងទេ។ ខ្លួនបានដឹងរឿងដែលជនរងគ្រោះខ្ចីលុយក្រុមហ៊ុន USD ៧០០ (ប្រាំពីរយ)ដុល្លារអាមេរិក លើសពីនេះខ្លួនមិនបានដឹងទេ។ រថយន្តម៉ាក **PORSCHE** ពណ៌ខ្មៅ ពាក់ផ្លាកលេខ 2AG-0667 ខ្លួនមិនស្គាល់ទេ។

- ជនជាប់ចោទឈ្មោះ [redacted] **XIANG PING** បានឆ្លើយថា៖ ខ្លួនមានមុខរបរជាជាងកាត់សក់ និងជាអ្នកគ្រប់គ្រងបុគ្គលិកស្នាក់នៅ។ អ្នកដែលគេចាប់មកជាមួយខ្លួន ខ្លួនមិនស្គាល់អ្នកណាម្នាក់ទេ។ នៅក្នុងក្រុមហ៊ុនខ្លួនជាអ្នកគ្រប់គ្រងការស្នាក់នៅរបស់បុគ្គលិកទាំងអស់។ ខ្លួនមិនស្គាល់ជនរងគ្រោះពីមុនមកទេ ទើបតែស្គាល់ពេលដែលសមត្ថកិច្ចឃាត់ខ្លួន។ ពីមុនធ្លាប់ឃើញជនរងគ្រោះ ប៉ុន្តែមិនស្គាល់ឈ្មោះ និងមិនមានទំនាក់ទំនងអ្វីនឹងគ្នាទេ។ ខ្លួនបានរៀបចំកន្លែងស្នាក់នៅឱ្យជនរងគ្រោះ ប៉ុន្តែមិនចាំថ្ងៃខែទេ គ្រាន់តែចាំថាមុនពេលសមត្ថកិច្ចឃាត់ខ្លួនប្រហែល ០១(មួយ)ខែ ទៅ០២(ពីរ)ខែ។ ចាប់តាំងពីសមត្ថកិច្ចឃាត់ខ្លួនរហូតមកដល់ពេលនេះ ខ្លួនចូលឆ្លើយបានចំនួន ០៣(បី)ដងហើយ លើកនេះជាលើកទី០៣។ ចម្លើយដែលខ្លួនធ្លាប់ឆ្លើយពីមុនមកខ្លួនចាំបានខ្លះៗ។ ចម្លើយដែលខ្លួនធ្លាប់ឆ្លើយពីដើមមកមិនមានការបង្ខិតបង្ខំទេ ចម្លើយទាំងនោះជាការពិត។ ខ្លួនពិតជាធ្លាប់បានឆ្លើយថា ខ្លួននិងជនរងគ្រោះមានទំនាក់ទំនងជាមួយគ្នា តាមរយៈជនរងគ្រោះបានឱ្យខ្លួនយកលុយទៅលោះជនរងគ្រោះពីក្រុមហ៊ុន ខាយប៉ ពិតមែន ជនរងគ្រោះឈ្មោះ [redacted] **YONG GUI** ធ្លាប់ប្រាប់ខ្លួនថា គាត់ជំពាក់លុយគេ នៅក្រុមហ៊ុនផ្សេង តើអាចឱ្យខ្លួន ជួយសងលុយទៅក្រុមហ៊ុនផ្សេងនិងជួយរកការងារឱ្យធ្វើផងបានអត់? ខ្លួនក៏ប្រាប់ថាអាចជួយបាន និងឱ្យជនរងគ្រោះធ្វើការដើម្បីសងលុយមកខ្លួនវិញ។ ខ្លួនពិតជាធ្លាប់បានឆ្លើយថា ខ្លួននិងជនរងគ្រោះមានទំនាក់ទំនងជាមួយគ្នា ហើយជនរងគ្រោះបានឱ្យខ្លួនយកលុយទៅលោះជនរងគ្រោះពីក្រុមហ៊ុន ខាយប៉ ពិតមែន។ ខ្លួនមិនបានជួយជនរងគ្រោះទ តែបានឱ្យលុយទៅជនរងគ្រោះខ្ចីដើម្បីចេញពីក្រុមហ៊ុន ឆាយណាថោន មិនមែនជួយពីក្រុមហ៊ុន ខាយប៉ ទេ។ ជនរងគ្រោះខ្ចីលុយរបស់ខ្លួនក្នុងអំឡុងខែមិនចាំ។ ប៉ុន្តែខ្លួនបានឱ្យលុយទៅជនរងគ្រោះខ្ចីចំនួន USD ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ឱ្យទៅឈ្មោះ [redacted] **YONG GUI**។ ជនរងគ្រោះទាំងពីរនាក់ប្ដីប្រពន្ធបានខ្ចីលុយខ្លួនសរុបចំនួន USD ៥៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក។ បន្ទាប់មកជនរងគ្រោះបានមកធ្វើការនៅក្រុមហ៊ុនរបស់ខ្លួន។



Scanned with CamScanner

ប៉ុន្តែមិនមែនធ្វើការដើម្បីសងបំណុលទេ បំណុលនោះគឺមានលុយពេលណា សងពេលនោះ។ ខ្លួនមិនបានដឹងថាក្រុមហ៊ុនផ្តល់ប្រាក់ខែឱ្យពួកគេម្នាក់ប៉ុន្មានទេ។ លុយដែលខ្លួនឱ្យជនរងគ្រោះខ្ចីនោះ គឺខ្លួនខ្ចីមកពីគេដែរ ខ្ចីពីឈ្មោះ [redacted] GE ចំនួន USD ៥៥,០០០ (ប្រាំម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ហើយយកទៅប្រគល់ឱ្យជនរងគ្រោះ ឈ្មោះ [redacted] YONG GUI ។ ខ្លួនបានទៅទទួលជនរងគ្រោះចេញពីក្រុមហ៊ុន ឆាយណាថោន មកក្រុមហ៊ុនរបស់ខ្លួន។ ពេលទៅទទួលនោះទៅប៉ុន្មាននាក់ខ្លួនមិនចាំទេ ខ្លួនបានចាំត្រឹមថាពេលទៅនោះ មានតែកុងឡានជនជាតិខ្មែរម្នាក់ មិនស្គាល់ឈ្មោះ និងមានអ្នកផ្សេងទៀតដែរ តែមិនចាំ។ ពេលដែលទៅដល់ក្រុមហ៊ុនឆាយណាថោន ខ្លួនមិនបានជួបជាមួយនឹងអ្នកណានៅក្រុមហ៊ុន ឆាយណាថោន ទេ គឺជួបតែជនរងគ្រោះ ឈ្មោះ [redacted] YONG GUI តែម្នាក់ ចំពោះប្រពន្ធរបស់ឈ្មោះ [redacted] YONG GUI ទាល់តែសងលុយឱ្យអស់សិន ទើបគេឱ្យចេញមក។ ខ្លួនបានឱ្យលុយទៅជនរងគ្រោះដើម្បីសងគេហើយ ប៉ុន្តែជនរងគ្រោះថានៅជំពាក់គេទៀត។ ថ្ងៃដែលទៅទទួលនោះគឺទទួលប្រពន្ធរបស់ឈ្មោះ [redacted] YONG GUI មកមុន រំលងបានប៉ុន្មានថ្ងៃក្រោយទើបទៅទទួលឈ្មោះ [redacted] YONG GUI មកតាមក្រោយ។ ពេលមកដល់ក្រុមហ៊ុនរបស់ខ្លួន ខ្លួនមិនបានដឹងថាក្រុមហ៊ុន ឱ្យពួកគេទាំងពីរនាក់ធ្វើការផ្នែកអ្វី និងស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកណាទេ ព្រោះខ្លួនគ្រាន់តែជាអ្នករៀបចំបន្ទប់ឱ្យស្នាក់នៅប៉ុណ្ណោះ ។ ចំពោះដំបងឆក់ ខ្លួនមិនបានដឹងទេ។ អ្នកទាំង០៤ ដែលសមត្ថកិច្ចឃាត់ខ្លួនមក ខ្លួនមិនស្គាល់ឈ្មោះទេ ថ្ងៃដែលសមត្ថកិច្ចចុះទៅឃាត់ខ្លួន ជនរងគ្រោះទាំងពីរនាក់មិននៅក្រុមហ៊ុនទេ ខ្លួនមិនដឹងថាពួកគេទៅណាទេ។ ក្រុមហ៊ុនដែលជនរងគ្រោះប្តូរទៅនោះ ជាក្រុមហ៊ុនតែមួយជាមួយក្រុមហ៊ុនរបស់ខ្លួនដែរ គ្រាន់តែមានទីតាំងអគារផ្សេងគ្នា ប៉ុន្តែជាក្រុមហ៊ុនតែមួយ។ ខ្លួនមិនបានគ្រប់គ្រងដល់ក្រុមហ៊ុនមួយទៀតនោះទេ ព្រោះក្រុមហ៊ុននោះមានអ្នកគ្រប់គ្រងផ្សេងទៀត។ ថ្ងៃដែលសមត្ថកិច្ចចុះឃាត់ខ្លួន ឈ្មោះ [redacted] GE ជាអ្នកទាក់ទងទៅអគារមួយទៀតឱ្យដឹកជនរងគ្រោះមកវិញ តែមិនដឹងថាទាក់ទងទៅអ្នកណាទេ ប៉ុន្តែឈ្មោះ [redacted] GE សមត្ថកិច្ចមិនបានឃាត់ខ្លួនមកជាមួយទេ។ ឈ្មោះ [redacted] GE នេះគឺអ្នកដែលឱ្យខ្លួនខ្ចីលុយ។ ខ្លួនដឹងថាឈ្មោះ [redacted] GE ជាអ្នកទាក់ទងទៅក្រុមហ៊ុនមួយទៀត ព្រោះជនរងគ្រោះបានប្រាប់ខ្លួន នៅពេលដែលខ្លួននៅសមត្ថកិច្ច។ មូលហេតុដែលជនរងគ្រោះប្តូរទៅអគារផ្សេងព្រោះ តែនៅក្រុមហ៊ុនរបស់ខ្លួនមិនមានការងារធ្វើទើបឱ្យជនរងគ្រោះទៅធ្វើការនៅក្រុមហ៊ុនផ្សេងទៀត។ ខ្លួនធ្លាប់បានវាយជនរងគ្រោះដែលជាប្រពន្ធរបស់ឈ្មោះ [redacted] YOUNG GUI ព្រោះតែគេធ្វើឱ្យខូចទូរស័ព្ទរបស់ខ្លួន ទើបខ្លួនទះគេ០១ដៃ។ ជនរងគ្រោះធ្វើឱ្យខូចទូរស័ព្ទរបស់ខ្លួន ព្រោះពេលនោះខ្លួន និងជនរងគ្រោះបានឈ្លោះគ្នា។ ពេលនោះមិនមានអ្នកផ្សេងទៀតទេ ខ្លួនមិនឃើញមានអ្នកផ្សេងយកខ្នោះដៃមកដាក់ជនរងគ្រោះទេ។ ខ្លួនមិនបានវាយជនរងគ្រោះប្រុសទេ។ ជនរងគ្រោះត្រូវបានគេវាយមុនពេលមកក្រុមហ៊ុនរបស់ខ្លួនទៀត ព្រោះពេលដែលជនរងគ្រោះមកដល់ក្រុមហ៊ុនរបស់ខ្លួន ខ្លួនឃើញភ្នែករបស់ជនរងគ្រោះស្រីមានស្នាមជាំ ហើយខ្លួនក៏បានឱ្យលុយទៅជនរងគ្រោះដើម្បីទៅព្យាបាល។ ខ្លួន និងឈ្មោះ [redacted] XIANG QUAN និងឈ្មោះ [redacted] QIAO LONG មិនបានវាយជនរងគ្រោះទេ។ លុយដែលយកទៅឱ្យជនរងគ្រោះខ្ចី ខ្លួនយកមកពីឈ្មោះ [redacted] GE លើកទី១ មានចំនួន USD ៣០,០០០ (បីម៉ឺន)ដុល្លារអាមេរិក និងលើកទី២ មានចំនួន USD ២៥,០០០ (ពីរម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ឱ្យទៅឈ្មោះ [redacted] YOUNG GUI ទាំងពីរលើក។ លុយចំនួន USD ៥៥,០០០ (ប្រាំម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ខ្លួនឱ្យទៅជនរងគ្រោះផ្ទាល់ មិនបានឱ្យទៅក្រុមហ៊ុនដែលជនរងគ្រោះ ជំពាក់លុយទេ។ ខ្លួនឱ្យលុយទៅជនរងគ្រោះខ្ចីព្រោះតែជនរងគ្រោះបានប្រាប់ខ្លួនថា ពួកគេបានជំពាក់លុយក្រុមហ៊ុន ហើយនៅក្រុមហ៊ុននោះត្រូវបានគេវាយធ្វើបាប និងរកលុយលែងបានទើបចង់មកធ្វើការ។

នៅក្រុមហ៊ុនរបស់ខ្លួនវិញដើម្បីរកលុយសងគេ ប៉ុន្តែប្រសិនបើជនរងគ្រោះព្រមធ្វើការនៅក្រុមហ៊ុនចាស់នោះបាន០១ឆ្នាំពេញ លុយដែលជនរងគ្រោះជំពាក់គេនោះ គឺមិនបាច់សងគេទេ។ ខ្លួនយកលុយទៅឱ្យជនរងគ្រោះនៅពេលដែលខ្លួនទៅទទួលជនរងគ្រោះចេញពីក្រុមហ៊ុន ខាយប៉ យកមកក្រុមហ៊ុន ជឹងឆាយ៥។ ជនរងគ្រោះធ្វើការនៅក្រុមហ៊ុនជឹងឆាយ៥ បានមួយខែ រកលុយមិនសូវបាន ជនរងគ្រោះបានសួរខ្លួនថា មានកន្លែងការងារថ្មីឬអត់ ហើយខ្លួនក៏យកជនរងគ្រោះមកធ្វើនៅទីតាំងថ្មី។ ខ្លួនយកជនរងគ្រោះដាក់ទីតាំងថ្មីមិនចាំថ្ងៃខែទេ។ ក្នុងខែសីហា នៅពេលដែលសមត្ថកិច្ចចុះមក ខ្លួនមិនបានដឹងរឿងដែលទាក់ទងនឹងការដឹកជនរងគ្រោះចេញទៅខាងក្រៅទេ។ សមត្ថកិច្ចឃាត់ខ្លួនខ្លួននៅក្រុមហ៊ុន ជឹងឆាយ៥ ពេលនោះខ្លួនកំពុងលេងទូរស័ព្ទ មិនបានដឹកជនរងគ្រោះចេញទៅខាងក្រៅទេ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] XIANKANG ទេ។ ពេលដែលសមត្ថកិច្ចចុះមកក្រុមហ៊ុន ជឹងឆាយ៥ ជនរងគ្រោះនៅក្រុមហ៊ុន ជាវសានទីង។ ក្រោយមកទើបទាក់ទងឱ្យគេដឹកជនរងគ្រោះមកក្រុមហ៊ុន ជឹងឆាយ៥ វិញ។ រឿងខ្នោះដៃ និងដំបងឆក់ ខ្លួនមិនបានដឹងទេ និងមិនដឹងថាជារបស់អ្នកណាទេ។ រថយន្តម៉ាក់ PORSCHE ពណ៌ខ្មៅ ពាក់ផ្លាកលេខ 2AG-0667 ខ្លួនមិនស្គាល់ទេ។

- ជនជាប់ចោទឈ្មោះ [redacted] XIANG QUAN បានឆ្លើយថា៖ ខ្លួនដឹងថាសមត្ថកិច្ចបានឃាត់ខ្លួនខ្លួនព្រោះរឿងអ្វី។ ខ្លួនដឹងថាជនរងគ្រោះធ្វើការនៅក្រុមហ៊ុន ជឹងឆាយ៥។ មុនមកក្រុមហ៊ុន ជឹងឆាយ៥ ខ្លួនមិនដឹងថាជនរងគ្រោះធ្វើការនៅក្រុមហ៊ុនណាទេ។ ខ្លួនចាប់ផ្តើមស្គាល់ជនរងគ្រោះនៅក្រុមហ៊ុន ជឹងឆាយ៥។ ប៉ុន្តែជនរងគ្រោះមកធ្វើការនៅជឹងឆាយ៥ ពេលណាខ្លួនមិនចាំទេ។ ពេលដែលជនរងគ្រោះមកធ្វើការនៅជឹងឆាយ៥ ខ្លួនធ្លាប់ជួបជនរងគ្រោះ តែខ្លួនមិនបាននាំជនរងគ្រោះទៅដាក់នៅក្នុងបន្ទប់ទេ។ ខ្លួនមិនធ្លាប់បានវាយទៅលើជនរងគ្រោះទេ ដាក់ខ្នោះដៃក៏អត់ដែរ។ ខ្លួនធ្លាប់ឃើញជនរងគ្រោះប៉ុន្តែមិនស្គាល់ឈ្មោះទេ។ ខ្លួនមិនបានបង្ខាំងជនរងគ្រោះទេ។ ខ្លួនធ្វើការនៅជឹងឆាយ៥ ជាអ្នកទិញឥវ៉ាន់។ ថ្ងៃដែលសមត្ថកិច្ចចុះឃាត់ខ្លួន ខ្លួនមិនមែនជាអ្នកដែលនាំជនរងគ្រោះចេញពីក្រុមហ៊ុន ជាវសានទីង ទៅក្រុមហ៊ុន ជឹងឆាយ៥ វិញទេ។ ខ្លួនមិនបានជិះរថយន្តម៉ាក PORSCHE ពណ៌ខ្មៅ ពាក់ផ្លាកលេខ 2AG-0667 ទេ ហើយខ្លួនក៏មិនស្គាល់ម្ចាស់រថយន្តនេះដែរ។

- ជនជាប់ចោទឈ្មោះ [redacted]QIAO LONG បានឆ្លើយថា៖ ខ្លួនធ្វើការនៅក្រុមហ៊ុន ជឹងឆាយ៥ ផ្នែកកត់ត្រាបុគ្គលិកចេញចូលធ្វើការ។ ឈ្មោះ [redacted] GE ជាថៅកែរបស់ខ្លួន។ ខ្លួនមិនស្គាល់ជនរងគ្រោះទាំងពីរនាក់នោះទេ ហើយក៏មិនចាំថាពួកគេមកធ្វើការនៅក្រុមហ៊ុន ជឹងឆាយ៥ ពេលណាដែរ។ ខ្លួនគ្រាន់តែដឹងថាជនរងគ្រោះធ្វើការនៅក្រុមហ៊ុន ជឹងឆាយ៥ ព្រោះខ្លួនធ្លាប់ឃើញ។ ពីមុនមកជនរងគ្រោះធ្វើការនៅឯណាខ្លួនមិនដឹងទេ។ ខ្លួនមិនបានទាមទារប្រាក់ពីជនរងគ្រោះចំនួន USD ៧០,០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ពេលដែលជនរងគ្រោះចង់ចាកចេញពីក្រុមហ៊ុននោះទេ។ ពេលដែលសមត្ថកិច្ចចុះធ្វើការតាមបណ្តឹងរបស់ជនរងគ្រោះ ខ្លួនមិនដឹងថាអ្នកណាដឹកជនរងគ្រោះទៅណាទេ ខ្លួនមិនបានឱ្យគេដឹកជនរងគ្រោះទៅក្រុមហ៊ុន ជាវសានទីង ទេ។ រឿងបង្ខាំងមនុស្ស ប្រើអំពើហិង្សា និងលក់ដូរមនុស្សខ្លួនមិនដឹងទេ។ នៅក្នុងក្រុមហ៊ុនខ្លួនកត់ត្រានៅពេលដែលត្រូវបើកទ្វារ ឬបិទទ្វារ ខ្លួនគ្រប់គ្រងបន្ទប់ការិយាល័យ។ ខ្លួនមិនបានវាយ និងឆក់ទៅលើជនរងគ្រោះទេ រឿងខ្នោះដៃ និងដំបងឆក់ ក៏ខ្លួនមិនបានដឹងដែរ។ ពេលដែលសមត្ថកិច្ចឆែកឆេរការិយាល័យរបស់ខ្លួន មិនមានពិលឆក់ និងខ្នោះដៃទេ។ ពីមុនមកខ្លួនមិនធ្លាប់ឆ្លើយថាពេលសមត្ថកិច្ចឆែកឆេរបន្ទប់ការិយាល័យរបស់ខ្លួនមានរកឃើញពិលឆក់ទេ។ រថយន្តម៉ាក់ PORSCHE ពណ៌ខ្មៅ ពាក់ផ្លាកលេខ 2AG-0667 ខ្លួនមិនស្គាល់ទេ។%

- ជនជាប់ចោទឈ្មោះ [redacted] LIN JIAN បានឆ្លើយថា៖ ថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួន ខ្លួនបានដឹកជនរងគ្រោះមកពីក្រុមហ៊ុនជាវសានទីង មានអ្នកទាក់ទងឱ្យខ្លួនដឹកជនរងគ្រោះមក អ្នកដែលទាក់ទងមកខ្លួនមិនមែនជាអ្នកទាំង០៤ ដែលសមត្ថកិច្ចចាប់មកនោះទេ ក្រុមហ៊ុនជាអ្នកទាក់ទងទៅខ្លួន។ ខ្លួនមិនស្គាល់បួននាក់ដែលសមត្ថកិច្ចចាប់ខ្លួនមកនេះទេ។ នៅក្រុមហ៊ុន ខ្លួនធ្វើការផ្នែកដឹកជញ្ជូន។ ថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួន ខ្លួនដឹកជនរងគ្រោះជិះរថយន្តម៉ាក LEXUS បើតាមចាំពណ៌ស ជារថយន្តរបស់ខ្លួន។ ខ្លួនមិនស្គាល់ជនរងគ្រោះទាំងពីនាក់ទេ។ សមត្ថកិច្ចឃាត់ខ្លួនខ្លួននៅក្រុមហ៊ុន ជឹងឆាយ៥ ពេលនោះខ្លួនមិនដឹងថាហេតុអ្វីបានជាសមត្ថកិច្ចឃាត់ខ្លួនខ្លួនទេ គ្រាន់តែខ្លួនដឹកជនរងគ្រោះមកដល់ក្រុមហ៊ុន ជឹងឆាយ៥ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ នៅលើរថយន្តពេលដែលឆែកទៅមិនមានដំបងឆក់ទេ។ រថយន្តម៉ាក់ PORSCHE ពណ៌ខ្មៅ ពាក់ផ្លាកលេខ 2AG-0667 ខ្លួនមិនស្គាល់ទេ។ ឈ្មោះ [redacted] XIANKANG ក៏ខ្លួនមិនស្គាល់ដែរ។

- ក្រឡាបញ្ជីអានពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] YONG GUI។

- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖ ក្រោយពីបានបញ្ចប់កិច្ចពិភាក្សាដេញដោល និងបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរួចមក តុលាការយល់ឃើញថាការបង្ខាំងមនុស្ស ដែលប្រព្រឹត្តនៅក្រុមហ៊ុនជឹងឆាយ៥ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ពិតជាមានអង្គហេតុដែលចាប់ឃុំឃាំង និងបង្ខាំងមនុស្សដោយខុសច្បាប់, អំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងអំពើលក់ដូរមនុស្សដោយមានគោលដៅ ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] BING LONG, ឈ្មោះ [redacted] XIANG QUAN, ឈ្មោះ [redacted] XIANG PING, ឈ្មោះ [redacted] LIN JIAN និងឈ្មោះ [redacted] QIAO LONG ពិតប្រាកដមែន ដែលអំពើនេះត្រូវបានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា២៥៣, មាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ** និង**មាត្រា១៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ** និងអំពើលក់ដូរមនុស្ស ដោយមានគោលដៅ ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] XIANKANG និងបទល្មើសសម្អាតប្រាក់ផងដែរ ដូចនេះ អំពើរបស់ជនជាប់ចោទទាំង០៦រូប បានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ប៉ះពាល់ដល់សិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូរ ក៏ដូចជាប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសជាតិផងដែរ ជនជាប់ចោទទាំង០៥រូប មានសមត្ថភាព និងស្មារតីគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ដូចនេះស្នើសុំឱ្យសម្រេចតាមនីតិវិធីច្បាប់ និងសម្រេចក្នុងការបណ្តេញជនទាំងនេះចេញពីព្រះរាជាណាចក្រកម្ពុជា។

- សេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN ៖ ពាក់ព័ន្ធនឹងការចោទប្រកាន់មកលើកូនក្តីរបស់ខ្លួនពីបទ ជួញដូរមនុស្សដោយខុសច្បាប់ និងហិង្សាដោយមានស្ថានទម្ងន់ទោស ខ្លួនសូមធ្វើសេចក្តីសន្និដ្ឋានឆ្លើយតបដូចតទៅ៖ ពាក់ព័ន្ធនឹងករណីនេះ បើពិនិត្យទៅលើសំណុំរឿង និងចម្លើយដែលកូនក្តីរបស់ខ្លួនបានឆ្លើយ ឃើញថា នៅក្រុមហ៊ុន ខាយប៉ កូនក្តីរបស់ខ្លួនគ្រាន់តែជាបុគ្គលិកដែលគ្រប់គ្រងមួយផ្នែកមួយដែលតូច គឺផ្នែកសម្ភារៈ ហើយទទួលបានប្រាក់ខែតែប៉ុណ្ណោះ ជាទូទៅក្រុមហ៊ុនមួយមានអ្នកគ្រប់គ្រងទូទៅ ដូច្នេះរាល់ការសម្រេចចិត្តមិនមែនកូនក្តីរបស់ខ្លួនជាអ្នកសម្រេចចិត្តថាត្រូវធ្វើអ្វីនោះទេ គឺមានអ្នកគ្រប់គ្រងរបស់កូនក្តីរបស់ខ្លួនជាអ្នកសម្រេច ជាក់ស្តែងកូនក្តីរបស់ខ្លួនក៏បានឆ្លើយនៅក្នុងសវនាការនេះដែរថា គាត់មានមេរបស់គាត់ម្នាក់ទៀត ដូច្នេះប្រាក់ខែរបស់ក្រុមហ៊ុន គឺបើកពីអ្នកគ្រប់គ្រង ដូចអ្វីដែលជនរងគ្រោះបានឆ្លើយបញ្ជាក់ថាក្រុមហ៊ុនបានលក់គាត់ទៅឱ្យក្រុមហ៊ុនផ្សេងទៀត។ ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីហិង្សាវិញឃើញថា ចម្លើយដែលបានឆ្លើយពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌,



Scanned with CamScanner

ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ រហូតដល់ពេលសវនាការនេះ គឺចម្លើយមានការកែប្រែ ដែលចម្លើយនេះជាចម្លើយដែលពិតប្រាកដ ជាចម្លើយដែលឆ្លើយដោយឆន្ទៈ ដែលអាចឱ្យតុលាការបញ្ជាក់បាន ថាកូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ ពាក់ព័ន្ធនឹងការដែលជនរងគ្រោះទាំងពីរនាក់ចាកចេញ ពីក្រុមហ៊ុន កូនក្តីរបស់ខ្លួនបានបញ្ជាក់ហើយថាព្រោះតែជនរងគ្រោះប្រើប្រាស់គ្រឿងញៀន ដូច្នេះក្រុមហ៊ុន បានបណ្តេញចេញ ដូច្នេះសកម្មភាពរបស់កូនក្តីរបស់ខ្លួនមិនមែនដូចអ្វីដែលតុលាការចោទប្រកាន់ទេ ដែលថា កូនក្តីរបស់ខ្លួនបានប្រើអំពើហិង្សាទៅលើជនរងគ្រោះ និងបានលក់ដូរមនុស្សទៅឱ្យកន្លែងធ្វើការថ្មី ដូច្នេះពុំមាន ធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ដូចនេះស្នើសុំឱ្យក្រុមប្រឹក្សាពិចារណាឱ្យកូនក្តីរបស់ខ្លួន រួចផុតពីបទចោទ។

- សេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] XIANG QUAN, ឈ្មោះ [redacted] XIANG PING, ឈ្មោះ [redacted] LIN JIAN និងឈ្មោះ [redacted] QIAO LONG៖ យោង ទៅតាមការសិក្សាសំណុំរឿង និងការសួរដេញដោលដោយផ្ទាល់នៅក្នុងសវនាការមុននេះឃើញថា ការចោទប្រកាន់ របស់តំណាងអយ្យការ ពាក់ព័ន្ធការជួញដូរ និងលក់ដូរមនុស្សដោយមានគោលដៅ តាមមាត្រា១៥ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទនេះ គឺកូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តទេ។ ចម្លើយដែល កូនក្តីរបស់ខ្លួនបានឆ្លើយតាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌, ដំណាក់កាលអយ្យការនិងដំណាក់កាល ចៅក្រមស៊ើបសួរ គឺជាចម្លើយតែមួយទេ គឺកូនក្តីរបស់ខ្លួនមិនបានយកលុយ USD ៥៥,០០០ (ប្រាំម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ទៅឱ្យក្រុមហ៊ុន ខាយប៉ ឬក្រុមហ៊ុនឆាយណាថោនទេ គឺកូនក្តីរបស់ខ្លួនបានឱ្យលុយទៅជនរងគ្រោះ ដោយផ្ទាល់ ព្រោះមានការស្នើសុំពីជនរងគ្រោះសុំខ្ចីប្រាក់ដើម្បីបង់ទៅលើបំណុលដែលជនរងគ្រោះជំពាក់គេព្រោះ ចង់ប្តូរកន្លែងធ្វើការ នៅក្នុងរបាយការណ៍ក៏មានបញ្ជាក់ដែរថាជនរងគ្រោះចង់ប្តូរព្រោះចង់បានប្រាក់ខែច្រើន ហើយនៅពេលដែលមកដល់ក្រុមហ៊ុន ជឹងឆាយ៥ គឺដូចកូនក្តីរបស់ខ្លួនបានបញ្ជាក់ថាជនរងគ្រោះមកមិនទាន់ បានធ្វើការអ្វីទេ។ កូនក្តីរបស់ខ្លួនបានយកលុយពីឈ្មោះ [redacted] GE ចំនួន USD ៥៥,០០០ (ប្រាំម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ឱ្យទៅឈ្មោះ [redacted] YONG GUI ដូចដែលអម្បាញ់មិញនេះលោកស្រី ក្រឡាបញ្ជី បានអាននូវ អំណានចម្លើយដែលបញ្ជាក់ថា កូនក្តីរបស់ខ្លួនបានយកលុយឱ្យជនរងគ្រោះមែន ប៉ុន្តែឱ្យជនរងគ្រោះបង់ទៅ ក្រុមហ៊ុនដើម្បីចេញពីការងារបង្ខិតបង្ខំ ដូចនេះបានបញ្ជាក់ច្បាស់ និងមានស្នាមមេដៃជាក់ជូនជាភស្តុតាង។ ជារួមពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការជួញដូរមនុស្សនេះ គឺកូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តទេ ពាក់ព័ន្ធនឹង ករណីហិង្សាវិញ ក្នុងសវនាការនេះ ឃើញថាកូនក្តីរបស់ខ្លួនទាំងអស់បានបញ្ជាក់ហើយថា កូនក្តីរបស់ខ្លួនមិនបាន ប្រើប្រាស់ហិង្សាទៅលើជនរងគ្រោះទេ ហើយការចោទប្រកាន់របស់មន្ត្រីនគរបាលយុត្តិធម៌ និងតំណាងអយ្យការ បានបញ្ជាក់ថាចោទប្រកាន់តែទៅលើពាក្យបណ្តឹងរបស់ជនរងគ្រោះទេ ដូច្នេះបើពិនិត្យមើលទៅមិនមានភស្តុតាង ណាមួយដែលបញ្ជាក់ទេ ទោះជាមានខ្នោះដៃ និងពិលឆក់ មែន ប៉ុន្តែមិនដឹងថាជារបស់អ្នកណាទេ។ ហើយ ទោះបីជាមានរបស់ចឹងមែន វាក៏ត្រូវការឱ្យមានភស្តុតាងទាក់ទងនឹងស្លាកស្នាម, សំបុត្រពេទ្យ ដែលជាក់មក ដើម្បីឱ្យព្យសកម្មដែលកើតឡើងស៊ីគ្នា ជាមួយនឹងការចោទប្រកាន់ ដូច្នេះពាក់ព័ន្ធនឹងករណីហិង្សានេះគឺកូនក្តី របស់ខ្លួនបានបដិសេធថា មិនបានប្រើហិង្សាទៅលើជនរងគ្រោះទេ ពាក់ព័ន្ធនឹងបញ្ហាបង្ខាំងដូចដែលខ្លួនលើកឡើង នៅចំណុចទី១ ពាក់ព័ន្ធនឹងការយកលុយទៅលោះបំណុល នេះបានន័យថាពាក់ព័ន្ធនឹងការងារ ដែលប្រទេស កម្ពុជាយើងក៏មានច្បាប់ការងារដែរ ទាក់ទងទៅនឹងទំនាក់ទំនងគតិយុត្តរវាងនិយោជក និងនិយោជិក តាមការ ប្រព្រឹត្តរបស់កូនក្តីរបស់ខ្លួន គឺឃើញថាកូនក្តីរបស់ខ្លួនទាំងបួននាក់ខុសនឹងច្បាប់ការងារត្រង់ថាយកមនុស្ស មកធ្វើការងារដើម្បីដោះបំណុល នេះវាខុសនឹងច្បាប់ការងារមែន ប៉ុន្តែមិនមែនជាការឃុំឃាំង ឬការបង្ខាំង មនុស្សដោយខុសច្បាប់ទេ។ មួយវិញទៀតកូនក្តីរបស់ខ្លួនឈ្មោះ [redacted] LIN JIAN ឃើញថាគាត់មិនបានប្រព្រឹត្ត៕

អ្វីទេ គ្រាន់តែគាត់ដឹកជនរងគ្រោះមកដល់ក្រុមហ៊ុនភ្លាម ខាងសមត្ថកិច្ចក៏ឃាត់ខ្លួនគាត់តែម្តង ហើយបែរជាចោទរួមគ្នាថាបាន ជួញដូរមនុស្ស ,បង្ខាំង និងប្រើអំពើហិង្សា។ ដូច្នេះតាមការបកស្រាយរបស់ខ្លួនមួយចំណុចម្តងៗ ខ្លួនសន្និដ្ឋានថា កូនក្តីរបស់ខ្លួនពិតជាមិនបានធ្វើអំពើខុសច្បាប់ដូចការចោទប្រកាន់ទេ ខ្លួនសូមសំណូមពរ និងសង្ឃឹមថា ប្រធានក្រុមប្រឹក្សា និងចៅក្រមក្រុមប្រឹក្សា មេត្តាពិចារណាឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទ ជាពិសេសលុបចោលការសំណូមពររបស់តំណាងអយ្យការដែលសូមឱ្យបណ្តេញកូនក្តីរបស់ខ្លួនចេញពីព្រះរាជាណាចក្រកម្ពុជា ព្រោះថាសព្វថ្ងៃកូនក្តីរបស់ខ្លួនមានការងារដែលត្រូវធ្វើនៅព្រះរាជាណាចក្រកម្ពុជាដែរ។

- សេចក្តីសន្និដ្ឋានរបស់លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] XIANKANG៖ ក្នុងសំណុំរឿងនេះដែរកូនក្តីរបស់ខ្លួនមិនបាននៅក្នុងអង្គសវនាការនេះទេ ជាក់ស្តែងកូនក្តីរបស់ខ្លួនជាប់ចោទ ព្រោះកូនក្តីរបស់ខ្លួនជាម្ចាស់រថយន្តម៉ាក់ PORSCHE ដែលត្រូវបានសមត្ថកិច្ចដកហូតនៅកន្លែងកើតហេតុផ្ទាល់ ខ្លួនសូមបញ្ជាក់ផងដែលថាតាមពាក្យបណ្តឹងរបស់ជនរងគ្រោះ គឺមិនមានចម្លើយណាមួយដែលពាក់ព័ន្ធទៅនឹងឈ្មោះកូនក្តីរបស់ខ្លួន និងម៉ាករថយន្តរបស់កូនក្តីរបស់ខ្លួនទេ។ តាមចម្លើយរបស់ជនជាប់ចោទទាំង០៥នាក់នេះដែរ ក៏បានបញ្ជាក់ច្បាស់ដែលថាពួកគេមិនស្គាល់រថយន្តម៉ាក់ PORSCHE ពណ៌ខ្មៅ និងឈ្មោះកូនក្តីរបស់ខ្លួនទេ ដូច្នេះស្នើសុំមេត្តាសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទ និងសម្រេចប្រគល់រថយន្តម៉ាក់ PORSCHE ពណ៌ខ្មៅ នេះជូនទៅម្ចាស់ដើមវិញ។

- សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN ៖ ខ្លួនស្នើសុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទ។

- សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] XIANG PING ៖ ខ្លួនស្នើសុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទ។

- សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] XIANG QUAN ៖ ខ្លួនស្នើសុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទ។

- សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] QIAO LONG ៖ ខ្លួនស្នើសុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទ។

- សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] LIN JIAN ៖ ខ្លួនស្នើសុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទ។

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹង
ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានកត់សម្គាល់របស់តំណាងអយ្យការប្តឹងសុំ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានលោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តព្រះសីហនុ

## យល់ឃើញថា

១. ជនជាប់ចោទឈ្មោះ [redacted] LIN JIAN ភេទប្រុស, ឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN ភេទប្រុស, ឈ្មោះ [redacted] XIANG QUAN ភេទប្រុស, ឈ្មោះ [redacted] XIANG PING ភេទប្រុស, ឈ្មោះ [redacted] QIAO LONG៚



Scanned with CamScanner

ភេទប្រុស ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះពីបទ **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌ**, បទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ** និងបទ **អំពើលក់ដូរមនុស្សដោយមានគោលដៅ** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា១៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនជឹងឆាយ៥ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ និងឈ្មោះ[redacted] XIANKANG ភេទប្រុស ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះពីបទ **អំពើលក់ដូរមនុស្សដោយមានគោលដៅ** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា១៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ** និងបទ **សម្អាតប្រាក់** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា៣៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម** ប្រព្រឹត្តនៅខេត្តព្រះសីហនុ កាលពីអំឡុងឆ្នាំ២០២២ តាមដីកាដំណោះស្រាយលេខ: ៤៤៤ ដ.ដ.ស/ជ/២២ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ របស់សាលាដំបូងខេត្តព្រះសីហនុ ដូចនេះតុលាការអាចទទួលយកមកធ្វើការជំនុំជម្រះលើជនជាប់ចោទបានតាមមាត្រា២៨៩ និងមាត្រា២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. អង្គហេតុដែលទទួលរងនូវការចោទប្រកាន់ ត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងឆ្នាំ២០២២ ដូច្នេះអំពើនេះត្រូវស្ថិតក្នុងវិសាលភាពនៃ**ក្រមព្រហ្មទណ្ឌ**, **ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ និងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម** និងទីកន្លែងប្រព្រឹត្តបទល្មើសនៅខេត្តព្រះសីហនុ ដូចនេះសាលាដំបូងខេត្តព្រះសីហនុមានសមត្ថកិច្ចស្របតាមមាត្រា២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣. តាមអំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] JIA XU និងឈ្មោះ [redacted] YONG GUI នៅដំណាក់សមត្ថកិច្ច បានឆ្លើយបញ្ជាក់យ៉ាងច្បាស់ថា: កាលពីអំឡុងខែមេសា ជនជាប់ចោទឈ្មោះ [redacted] BING LONG បានឃុំដើមបណ្តឹងឈ្មោះ [redacted] JIA XU និងឈ្មោះ [redacted] YONG GUI ដើម្បីបង្ខំឱ្យធ្វើការអនឡាញ, បានវាយពួកគេទាំងពីរ និងបានធក់ទៅលើឈ្មោះ [redacted] YONG GUI។ លើសពីនេះ នៅអំឡុងខែមិថុនា ជនជាប់ចោទឈ្មោះ[redacted]BING LONG បានលក់ពួកគេទៅឱ្យក្រុមហ៊ុន ជឹងឆាយ៥ ដែលមានជនជាប់ចោទឈ្មោះ [redacted] XIANG PING និងជនមិនស្គាល់ឈ្មោះ០២(ពីរ)នាក់ផ្សេងទៀត មកដឹកពួកគេចេញពីក្រុមហ៊ុន ខាយប៉ ទៅក្រុមហ៊ុន ជឹងឆាយ៥។ ពេលទៅដល់ក្រុមហ៊ុន ជឹងឆាយ៥ ដើមបណ្តឹងឈ្មោះ [redacted]JIA XU និងឈ្មោះ [redacted]YONG GUI ត្រូវបានជនជាប់ចោទឈ្មោះ [redacted]QIAO LONG បញ្ជាឱ្យឈ្មោះ [redacted] XIANG PING និងឈ្មោះ [redacted] XIANG QUAN យកទៅឃុំទុកក្នុងបន្ទប់។ ជនជាប់ចោទឈ្មោះ [redacted] XIANG PING និងឈ្មោះ [redacted] XIANG QUAN បានដាក់ខ្នោះដៃជាប់ជាមួយនឹងជើងគ្រែ ហើយបានទះកំផ្លៀងដើមបណ្តឹងឈ្មោះ [redacted]A XU និងឈ្មោះ [redacted]ONG GUI និងបានទះក្បាល យកស្បែកជើងវាយក្បាលមកលើដើមបណ្តឹងឈ្មោះ [redacted]A XU។ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២២ ជនជាប់ចោទឈ្មោះ [redacted]QIAO LONG បានដឹកពួកគេយកទៅលក់នៅក្រុមហ៊ុន ជាវសានទីង។ នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ក្រុមហ៊ុន ជាវសានទីង បានឱ្យជនជាប់ចោទឈ្មោះ [redacted]LIN JIAN ដឹកពួកគេមកជឹងឆាយ៥ វិញ ហើយត្រូវបានសមត្ថកិច្ចរំដោះ។

៤. តាមអំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted]YAN បានឆ្លើយថា: ខ្លួនបានទៅធ្វើការនៅក្រុមហ៊ុន ខាយប៉ ជាមួយឈ្មោះ [redacted]BING LONG ដោយទទួលបានប្រាក់ខែ USD ១,០០០ (មួយពាន់)ដុល្លារអាមេរិក ជាបុគ្គលិកកុំព្យូទ័រ។ ខ្លួនធ្វើការបាន០៣(បី)ថ្ងៃ ខ្លួនបានសុំអ្នកគ្រប់គ្រងឈ្មោះ [redacted]BING LONG ឈប់ ព្រោះ/.



Scanned with CamScanner

តែការងារនេះ ជាការងារខុសច្បាប់ តែឈ្មោះ [redacted] BING LONG ឆ្លើយថា បើចង់ឈប់ ឱ្យខ្លួនសងប្រាក់គេ USD ២៦,០០០ (ពីរម៉ឺនប្រាំមួយពាន់)ដុល្លារអាមេរិក។ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ មានសមត្ថកិច្ចមកដល់ក្រុមហ៊ុន ខ្លួនក៏ប្រាប់សមត្ថកិច្ចឱ្យជួយខ្លួនចេញពីក្រុមហ៊ុន ពេលខ្លួនធ្វើការមានសម្ពាធណាស់។ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] BING LONG ពិតជាបានបង្ខាំងដើមបណ្តឹងឈ្មោះ [redacted] YAN ឱ្យធ្វើការពិតប្រាកដមែន ដោយហេតុថា ដើមបណ្តឹងឈ្មោះ [redacted] YAN ពិតជាមានវត្តមាននៅទីកន្លែងកើតហេតុ នៅពេលដែលសមត្ថកិច្ចចុះទៅទីតាំងកើតហេតុមែន និងរបាយការណ៍របស់សមត្ថកិច្ចបានបញ្ជាក់ថា ឈ្មោះ [redacted] YAN គឺជាជនរងគ្រោះ ក្នុងករណី លក់ដូរមនុស្សដោយមានគោលដៅ ពិតប្រាកដមែន។

៥. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN បានឆ្លើយថា: មូលហេតុដែលជនរងគ្រោះឆ្លើយថាខ្លួនជាអ្នកបង្ខាំងពួកគេ ព្រោះតែពេលដែលពួកគេចូលមកធ្វើការខ្លួនជាអ្នករៀបចំកន្លែងស្នាក់នៅឱ្យពួកគេ ដូច្នេះពួកគេរកអ្នកដែលបង្ខាំងពួកគេមិនឃើញ និងមិនដឹងឆ្លើយដាក់អ្នកណា ក៏ឆ្លើយដាក់ខ្លួនតែម្តង។ មូលហេតុដែលជនរងគ្រោះធ្វើការនៅក្រុមហ៊ុនរបស់ខ្លួនសុខៗ ក៏ប្តូរទៅក្រុមហ៊ុនផ្សេងវិញ ព្រោះក្រុមហ៊ុន រកឃើញថាទាំងពីរនាក់ប្តីប្រពន្ធប្រើប្រាស់គ្រឿងញៀន ក្រុមហ៊ុនក៏ឈប់ឱ្យពួកគេធ្វើការ។ អំឡុងពេលដែលជនរងគ្រោះនៅក្រុមហ៊ុនរបស់ខ្លួន ខ្លួនមិនបានវាយទៅលើជនរងគ្រោះ ឬបញ្ជាឱ្យគេវាយទៅលើជនរងគ្រោះទេ មិនបានប្រើដំបងឆក់ទេ។ ខ្លួនមិនបានលក់ជនរងគ្រោះឱ្យទៅក្រុមហ៊ុន ជីងឆាយ៥ ទេ។ ខ្លួនមិនបានទទួលលុយពីឈ្មោះ [redacted] XIANG PING ទេ។ តុលាការយល់ឃើញថា ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] LONG ហៅ [redacted] TIAN ខាងលើ ជាចម្លើយដោះសារដើម្បីឱ្យខ្លួនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌប៉ុណ្ណោះ ដោយហេតុថា តាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] JIA XU, ឈ្មោះ [redacted] YONG GUI និងឈ្មោះ [redacted] YAN បានបញ្ជាក់យ៉ាងច្បាស់ពីសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] BING LONG ដូចមានក្នុងសំអាងហេតុទី៣ និងទី៤។ មួយវិញទៀត ជនជាប់ចោទឈ្មោះ [redacted] BING LONG បានឆ្លើយនៅដំណាក់កាលសមត្ថកិច្ចថា: ជនរងគ្រោះឈ្មោះ [redacted] JIA XU និងឈ្មោះ [redacted] YONG GUI សុំចេញពីក្រុមហ៊ុនដោយខ្លួនឯង ដោយមានមិត្តភក្តិមកទទួល ប៉ុន្តែនាពេលសវនាការ ជនជាប់ចោទឈ្មោះ [redacted] BING LONG បានបញ្ជាក់ថា ក្រុមហ៊ុនបានបញ្ឈប់ពួកគេធ្វើការទៅវិញ ដោយផ្អែកលើកិច្ចសន្យាការងារ, ប័ណ្ណបង់សងក្រោយពេលបុគ្គលិកឈប់ពីការងារ។ ត្រង់ចំណុចខាងលើនេះ តុលាការយល់ឃើញថា ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] BING LONG មានភាពមិនច្បាស់លាស់ដែលអាចឱ្យតុលាការជឿជាក់បានទេ។

៦. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] XIANG PING បានឆ្លើយថា: ជនរងគ្រោះឈ្មោះ [redacted] YONG GUI ធ្លាប់ប្រាប់ខ្លួនថា គាត់ជំពាក់លុយគេ នៅក្រុមហ៊ុនផ្សេង តើអាចឱ្យខ្លួនជួយសងលុយទៅក្រុមហ៊ុនផ្សេងនិងជួយរកការងារឱ្យធ្វើផងបានអត់? ខ្លួនក៏ប្រាប់ថាអាចជួយបាន និងឱ្យជនរងគ្រោះធ្វើការដើម្បីសងលុយមកខ្លួនវិញ។ ជនរងគ្រោះទាំងពីរនាក់ប្តីប្រពន្ធបានខ្ចីលុយខ្លួនសរុបចំនួន USD ៥៥0,000 **(ប្រាំម៉ឺនប្រាំពាន់)** ដុល្លារអាមេរិក។ បន្ទាប់មកជនរងគ្រោះបានមកធ្វើការនៅក្រុមហ៊ុនរបស់ខ្លួន។ ប៉ុន្តែមិនមែនធ្វើការដើម្បីសងបំណុលទេ បំណុលនោះ គឺមានលុយពេលណា សងពេលនោះ។ លុយដែលខ្លួនឱ្យជនរងគ្រោះខ្ចីនោះ គឺខ្លួនខ្ចីមកពីគេដែរ ខ្ចីពីឈ្មោះ [redacted] GE ចំនួន USD ៥៥,000 (ប្រាំម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ហើយយកទៅប្រគល់ឱ្យជនរងគ្រោះឈ្មោះ [redacted] YONG GUI ។ ថ្ងៃដែលទៅទទួលនោះ គឺទទួលប្រពន្ធរបស់ឈ្មោះ [redacted] YONG GUI មកមុន រំលងបានប៉ុន្មានថ្ងៃក្រោយទើបទៅទទួលឈ្មោះ [redacted] YONG GUI មកតាមក្រោយ។ ក្រុមហ៊ុននោះ ជាក្រុមហ៊ុនតែមួយ គ្រាន់តែមានទីតាំងផ្សេងគ្នា ប៉ុន្តែជាក្រុមហ៊ុនតែមួយ។%

ខ្លួនធ្លាប់បានវាយជនរងគ្រោះដែលជាប្រពន្ធរបស់ឈ្មោះ [redacted] YOUNG GUI ព្រោះតែគេធ្វើឱ្យខូចទូរស័ព្ទរបស់ខ្លួន ទើបខ្លួនទះគេ០១ដៃ ពេលនោះមិនមានអ្នកផ្សេងទៀតទេ មិនឃើញមានអ្នកផ្សេងយកខ្នោះដៃមកដាក់ជនរងគ្រោះទេ។ ខ្លួនមិនបានវាយជនរងគ្រោះប្រុសទេ។ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] XIANG PING មិនបានឱ្យប្រាក់ទៅដើមបណ្ដឹងឈ្មោះ [redacted] YONG GUI នោះទេ តែបានឱ្យប្រាក់ទៅជនជាប់ចោទឈ្មោះ [redacted] BING LONG។ ប្រាក់នេះទៀតសោត ក៏មិនមែនជាប្រាក់ដែលដើមបណ្ដឹងឈ្មោះ [redacted] YONG GUI បានខ្ចីពីជនជាប់ចោទឈ្មោះ [redacted] XIANG PING ដែរ ប៉ុន្តែតុលាការមានភាពជឿជាក់ថា ប្រាក់នេះ ជាប្រាក់ដែលទិញដើមបណ្ដឹងឈ្មោះ [redacted] JIA XU និងឈ្មោះ [redacted] YONG GUI ពីជនជាប់ចោទឈ្មោះ [redacted] BING LONG មកធ្វើការនៅក្រុមហ៊ុនជីនឆាយ៥ ដោយផ្អែកទៅតាមចម្លើយរបស់ដើមបណ្ដឹងឈ្មោះ [redacted] JIA XU និងឈ្មោះ [redacted] YONG GUI។ មួយវិញទៀត តាមចម្លើយរបស់ដើមបណ្ដឹងឈ្មោះ [redacted] JIA XU និងឈ្មោះ [redacted] YONG GUI ដូចមានក្នុងសំអាងហេតុទី៣ បានបញ្ជាក់យ៉ាងច្បាស់ថា ជនជាប់ចោទឈ្មោះ [redacted] XIANG PING បានដាក់ខ្លួននៅក្នុងបន្ទប់ដោយដាក់ខ្នោះដៃជាប់ជាមួយនឹងជើងគ្រែ និងបានវាយមកលើខ្លួន ដូចនេះតុលាការមានភាពជឿជាក់ថា ជនជាប់ចោទឈ្មោះ [redacted] XIANG PING ពិតជាបានបង្ខាំង, វាយ និងទទួលដើមបណ្ដឹងឈ្មោះ [redacted] JIA XU និងឈ្មោះ [redacted] YONG GUI ពីក្រុមហ៊ុនខាយប៉ មកក្រុមហ៊ុន ជីងឆាយ៥ ពិតប្រាកដមែន។

៧. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] XIANG QUAN បានឆ្លើយថា: ខ្លួនចាប់ផ្តើមស្គាល់ជនរងគ្រោះនៅក្រុមហ៊ុន ជីងឆាយ៥។ ប៉ុន្តែជនរងគ្រោះមកធ្វើការនៅជីងឆាយ៥ ពេលណាខ្លួនមិនចាំទេ។ ពេលដែលជនរងគ្រោះមកធ្វើការនៅ ជីងឆាយ៥ ខ្លួនធ្លាប់ជួបជនរងគ្រោះ តែខ្លួនមិនបាននាំជនរងគ្រោះទៅដាក់នៅក្នុងបន្ទប់ទេ។ ខ្លួនមិនធ្លាប់បានវាយទៅលើជនរងគ្រោះទេ ដាក់ខ្នោះដៃក៏អត់ដែរ។ ខ្លួនមិនបានបង្ខាំងជនរងគ្រោះទេ។ ខ្លួនធ្វើការនៅជីងឆាយ៥ ជាអ្នកទិញឥវ៉ាន់។ ថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួន ខ្លួនមិនមែនជាអ្នកដែលនាំជនរងគ្រោះចេញពីក្រុមហ៊ុន ជាវសានទីង ទៅក្រុមហ៊ុន ជីងឆាយ៥ ទេ។ តុលាការយល់ឃើញថា ការបដិសេធរបស់ជនជាប់ចោទ គ្រាន់តែជាចម្លើយដោះសារដើម្បីឱ្យខ្លួនរួចផុតពីការទទួលខុសត្រូវប៉ុណ្ណោះ ដោយហេតុថា ផ្អែកតាមចម្លើយរបស់ដើមបណ្ដឹងឈ្មោះ [redacted] JIA XU និងឈ្មោះ [redacted] YONG GUI និងរបាយការណ៍របស់សមត្ថកិច្ច បានបង្ហាញយ៉ាងច្បាស់ពីសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] XIANG QUAN ដែលបានបង្ខាំង, វាយ និងលក់ដូរដើមបណ្ដឹងឈ្មោះ [redacted] JIA XU និងឈ្មោះ [redacted] YONG GUI ពីក្រុមហ៊ុនមួយ ទៅក្រុមហ៊ុនមួយ។

៨. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] QIAO LONG បានឆ្លើយថា: ខ្លួនមិនស្គាល់ជនរងគ្រោះទាំងពីរនាក់នោះទេ ហើយក៏មិនចាំថាពួកគេមកធ្វើការនៅក្រុមហ៊ុន ជីងឆាយ៥ ពេលណាដែរ។ ខ្លួនគ្រាន់តែដឹងថាជនរងគ្រោះធ្វើការនៅក្រុមហ៊ុន ជីងឆាយ៥ ព្រោះខ្លួនធ្លាប់ឃើញ។ ខ្លួនមិនបានទាមទារប្រាក់ពីជនរងគ្រោះចំនួន USD ៧០,០០០ (ប្រាំពីរ)ម៉ឺនដុល្លារអាមេរិក ពេលដែលជនរងគ្រោះចង់ចាកចេញពីក្រុមហ៊ុននោះទេ។ ពេលដែលសមត្ថកិច្ចចុះធ្វើការតាមបណ្ដឹងរបស់ជនរងគ្រោះ ខ្លួនមិនដឹងថាអ្នកណាដឹកជនរងគ្រោះទៅណាទេ ខ្លួនមិនបានឱ្យគេទៅដឹកជនរងគ្រោះទៅក្រុមហ៊ុន ជាវសានទីង ទេ។ ខ្លួនមិនបានវាយ និងឆក់ទៅលើជនរងគ្រោះទេ រឿងខ្នោះដៃ និងដំបងឆក់ ក៏ខ្លួនមិនបានដឹងដែរ។ តុលាការយល់ឃើញថា ការបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] QIAO LONG ជាចម្លើយដោះសារដើម្បីឱ្យខ្លួនរួចផុតពីការទទួលខុសត្រូវប៉ុណ្ណោះ ដោយហេតុថា ដើមបណ្ដឹងឈ្មោះ [redacted] JIA XU និងឈ្មោះ [redacted] YONG GUI បានបញ្ជាក់យ៉ាងច្បាស់ថា ជនជាប់ចោទ៚

ឈ្មោះ [redacted]QIAO LONG បានបញ្ជាឱ្យជនជាប់ចោទឈ្មោះ [redacted]XIANG PING និងឈ្មោះ [redacted] XIANG QUAN ឱ្យយកជនរងគ្រោះទៅបង្ខាំង និងបានលក់ខ្លួនទៅឱ្យក្រុមហ៊ុន ជីវសានទីង។

៩. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] LIN JIAN បានឆ្លើយថា: ថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួន ខ្លួនបានដឹកជនរងគ្រោះមកពីក្រុមហ៊ុន ជាវសានទីង មានអ្នកទាក់ទងឱ្យខ្លួនដឹកជនរងគ្រោះមក អ្នកដែលទាក់ទងមកខ្លួនមិនមែនជាអ្នកទាំង០៤ ដែលសមត្ថកិច្ចចាប់មកនោះទេ ក្រុមហ៊ុនជាអ្នកទាក់ទងទៅខ្លួន។ ខ្លួនមិនស្គាល់បួននាក់នេះទេ។ នៅក្រុមហ៊ុន ខ្លួនធ្វើការផ្នែកដឹកជញ្ជូន។ តុលាការយល់ឃើញថា ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]LIN JIAN មិនអាចឱ្យតុលាការជឿជាក់បានទេ ដោយហេតុថា ជនជាប់ចោទឈ្មោះ [redacted]LIN JIAN បានបដិសេធថា ក្រុមហ៊ុនជាអ្នកទាក់ទងមកខ្លួនឱ្យដឹកជនរងគ្រោះ ប៉ុន្តែតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] LIN JIAN នៅដំណាក់កាលសមត្ថកិច្ច បានបញ្ជាក់ថា អ្នកគ្រប់គ្រងឈ្មោះ [redacted]QUAN បានទាក់ទងមកខ្លួន ដូចនេះតុលាការមានភាពជឿជាក់ថា ជនជាប់ចោទឈ្មោះ[redacted]LIN JIAN ជាបក្ខពួករបស់ជនជាប់ចោទឈ្មោះ [redacted] XIANG QUAN។

១០. យល់ឃើញថា វត្ថុដែលបានចាប់យកមានរថយន្តម៉ាក PORSCHE ពណ៌ខ្មៅ ពាក់ស្លាកលេខ: ភ្នំពេញ 2AG-0667 មានកម្មសិទ្ធិករ ជាជនជាប់ចោទឈ្មោះ[redacted] XIANKANG ផ្អែកតាមរបាយការណ៍លេខ: ៦៨៧ សក.ខសន/២២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ របស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ ដូចនេះតុលាការមានភាពជឿជាក់ថា ជនជាប់ចោទឈ្មោះ [redacted] XIANKANG មានការពាក់ព័ន្ធនឹងការទិញលក់ដើមបណ្តឹងឈ្មោះ [redacted]A XU និងឈ្មោះ[redacted] YONG GUI។

១១. អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] BING LONG ហៅ[redacted]TIAN, ឈ្មោះ [redacted] XIANG PING និងឈ្មោះ [redacted] XIANG QUAN ជាបទ **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា២៥៣ ចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ**, បទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា២១៨ ចំណុចទី២ និងទី៣ នៃក្រមព្រហ្មទណ្ឌ** និងបទ **អំពើលក់ដូរមនុស្សដោយមានគោលដៅ** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា១៥ កថាខណ្ឌទី២ ចំណុចទី៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនជឹងឆាយ៥ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។

១២. អំពើរបស់ជនជាប់ចោទឈ្មោះ[redacted] QIAO LONG ភេទប្រុស និងឈ្មោះ[redacted]LIN JIAN ភេទប្រុស ជាបទ **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា២៥៣ ចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ** និងបទ **អំពើលក់ដូរមនុស្សដោយមានគោលដៅ** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា១៥ កថាខណ្ឌទី២ ចំណុចទី៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនជឹងឆាយ៥ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។

១៣. អំពើរបស់ជនជាប់ចោទឈ្មោះ [redacted]XIANKANG ភេទប្រុស ជាបទ **អំពើលក់ដូរមនុស្សដោយមានគោលដៅ** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា១៥ កថាខណ្ឌទី២ ចំណុចទី៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ** និងបទ សម្អាតប្រាក់ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា៣៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម**។

១៤. តាមរយៈអង្គហេតុដែលជាធាតុសត្យានុម័តខាងលើ តុលាការអាចកំណត់បាននូវធាតុអត្តនោម័តរបស់ជនជាប់ចោទឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN ភេទប្រុស, ឈ្មោះ [redacted] XIANG PING ភេទប្រុស, ឈ្មោះ [redacted] XIANG QUAN ភេទប្រុស, ឈ្មោះ [redacted] QIAO LONG ភេទប្រុស, ឈ្មោះ [redacted] LIN JIAN ភេទប្រុស និងឈ្មោះ [redacted] XIANKANG ភេទប្រុស ពិតជាមានចេតនាក្នុងការប្រព្រឹត្តដូចមានក្នុងបទចោទប្រកាន់ពិតប្រាកដមែន។

១៥. ជនជាប់ចោទឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN ភេទប្រុស កើតឆ្នាំ១៩៨៣, ឈ្មោះ [redacted] XIANG PING ភេទប្រុស កើតឆ្នាំ១៩៩៤, ឈ្មោះ [redacted] XIANG QUAN ភេទប្រុស កើតឆ្នាំ១៩៩១, ឈ្មោះ [redacted] QIAO LONG ភេទប្រុស កើតឆ្នាំ១៩៩៣, ឈ្មោះ XU LIN JIAN ភេទប្រុស កើតឆ្នាំ១៩៨៦ និងឈ្មោះ [redacted] XIANKANG ភេទប្រុស កើតឆ្នាំ១៩៨០ ដូចនេះជានីតិជន មានស្មារតីគ្រប់គ្រាន់នៅពេលប្រព្រឹត្តបទល្មើសនេះ និងពុំមានសញ្ញាណាមួយបញ្ជាក់ពីវិបល្លាសស្មារតីឡើយ ហេតុដូចនេះជនជាប់ចោទឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN ភេទប្រុស, ឈ្មោះ [redacted] XIANG PING ភេទប្រុស, ឈ្មោះ [redacted] XIANG QUAN ភេទប្រុស, ឈ្មោះ [redacted] QIAO LONG ភេទប្រុស, ឈ្មោះ [redacted] LIN JIAN ភេទប្រុស និងឈ្មោះ [redacted] XIANKANG ភេទប្រុស ជាសមត្ថជនដែលមានសមត្ថភាពយល់ដឹងពីអំពើរបស់ខ្លួន និងអាចទទួលខុសត្រូវព្រហ្មទណ្ឌ ស្របតាម**មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ**។

១៦. យោងតាមសំអាងហេតុដូចបានចង្អុលបង្ហាញខាងលើ មានធាតុផ្សំនៃបទល្មើស និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលអាចឱ្យតុលាការប្រកាសពីពិរុទ្ធភាពលើជនជាប់ចោទ៖

១៦.១. ឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN, ឈ្មោះ [redacted] XIANG PING និងឈ្មោះ [redacted] XIANG QUAN ជាបទ **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា២៥៣ ចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ**, បទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា២១៨ ចំណុចទី២ និងទី៣ នៃក្រមព្រហ្មទណ្ឌ** និងបទ **អំពើលក់ដូរមនុស្សដោយមានគោលដៅ** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា១៥ កថាខណ្ឌទី២ ចំណុចទី៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនជឹងឆាយ៥ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២,

១៦.២. ឈ្មោះ [redacted] QIAO LONG ភេទប្រុស និងឈ្មោះ [redacted] LIN JIAN ភេទប្រុស ជាបទ **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា២៥៣ ចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ** និងបទ **អំពើលក់ដូរមនុស្សដោយមានគោលដៅ** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា១៥ កថាខណ្ឌទី២ ចំណុចទី៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនជឹងឆាយ៥ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ និង

១៦.៣. ឈ្មោះ [redacted] XIANKANG ភេទប្រុស ជាបទ **អំពើលក់ដូរមនុស្សដោយមានគោលដៅ** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា១៥ កថាខណ្ឌទី២ ចំណុចទី៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ** និងបទ **សម្អាតប្រាក់** បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា៣៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម**។



Scanned with CamScanner

ដូចនេះ គប្បីតុលាការសម្រេចពិចារណាអំពីការប្រកាសមូលទោសដោយផ្អែកតាមបញ្ញត្តិនៃមាត្រា៩៦ និងមាត្រា៩៧ នៃក្រមព្រហ្មទណ្ឌ។

១៧. គ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកដែលអាចឱ្យតុលាការប្រកាសពីពិរុទ្ធភាពលើជនជាប់ចោទ ឈ្មោះ [redacted]QIAO LONG ភេទប្រុស និងឈ្មោះ [redacted] LIN JIAN ភេទប្រុស ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនជឹងឆាយ៥ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ដូចនេះគប្បីតុលាការសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] QIAO LONG ភេទប្រុស និងឈ្មោះ [redacted] LIN JIAN ភេទប្រុស រួចខ្លួនពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនជឹងឆាយ៥ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ស្របតាមបញ្ញត្តិនៃ**មាត្រា៣៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ**។

១៨. ចំពោះសេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកតំណាងអយ្យការ, សេចក្តីសន្និដ្ឋានរបស់លោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងសំណូមពររបស់ជនជាប់ចោទ តុលាការលើកយកមកពិចារណា និងសម្រេចតាមច្បាប់។

១៩. ផ្អែកតាមដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខៈ ៤៩៤៥ ត.ព.រ/ឃ/២២ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តព្រះសីហនុ បានសម្រេចបង្កកទ្រព្យសម្បត្តិរបស់ជនជាប់ចោទឈ្មោះ [redacted] XIANKANG ជារថយន្តម៉ាក PORSCHE ពណ៌ខ្មៅ ពាក់ស្លាកលេខៈ ភ្នំពេញ 2AG-0667 តុលាការយល់ឃើញថា ទ្រព្យសម្បត្តិខាងលើ ជាមធ្យោបាយនៃការប្រព្រឹត្តបទល្មើស ហេតុដូច្នេះគប្បីតុលាការសម្រេចរឹបអូស តាមបញ្ញត្តិនៃ**មាត្រា៣២ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម**។

២០. ផ្អែកតាមកំណត់ហេតុចាប់យកវត្ថុតាងក្នុងបទល្មើសជាក់ស្តែង ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២២ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ និងកំណត់ហេតុទទួលវត្ថុចាប់យកលេខៈ ៥៨៣ វ.ត/២២ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ បានបង្ហាញឱ្យឃើញថា វត្ថុចាប់យក រួមមានៈ

២០.១. ទូរស័ព្ទដៃចំនួន ០៣(បី)គ្រឿង មានម៉ាក IPHONE XR ពណ៌ខ្មៅ, ម៉ាក IPHONE X ពណ៌ខ្មៅ និងម៉ាក IPHONE13 ពណ៌ខៀវ។

២០.២. ទូរស័ព្ទដៃចំនួន ០២(ពីរ)គ្រឿង មានម៉ាក IPHONE 13 Pro Max ពណ៌ខៀវ និង ពណ៌ស្លែ។

២០.៣. ទូរស័ព្ទដៃចំនួន ០១(មួយ)គ្រឿង មានម៉ាក IPHONE13 Pro Max ពណ៌ខៀវ។

២០.៤. ទូរស័ព្ទដៃចំនួន ០២(ពីរ)គ្រឿង មានម៉ាក IPHONE13 Pro Max ពណ៌ខៀវ និងម៉ាក IPHONE7 ពណ៌ខ្មៅ។

២០.៥. ទូរស័ព្ទដៃចំនួន ០២(ពីរ)គ្រឿង មានម៉ាក REDMI ពណ៌ខៀវ និងម៉ាក IPHONE13 ពណ៌ខៀវ។

២០.៦. រថយន្តម៉ាក PORSCHE ពណ៌ខ្មៅ ពាក់ស្លាកលេខៈ ភ្នំពេញ 2AG-0667

២០.៧. ពិលធក់ ចំនួន ០៤(បួន)គ្រឿង, ខ្នោះដៃ ចំនួន ០២(ពីរ)គូរ និងកូនសោរខ្នោះ ចំនួន ០២(ពីរ)គូ។៚



Scanned with CamScanner

២០.៨. នាឡិកាដៃ ចំនួន ០២(ពីរ)គ្រឿង ម៉ាក LONGINES មានតួលោហៈពណ៌លឿង ខ្សែស្បែកពណ៌ខ្មៅ។

២០.៩. ប្រាក់យ័ន្ត ចំនួន ៥០០(ប្រាំរយ)យ័ន្ត, ប្រាក់ ចំនួន ២២៣.០០០ (ពីររយម្ភៃបីពាន់) រៀល។

២០.១០. កាបូបលុយ ពណ៌ខ្មៅ ចំនួន ០១(មួយ)។

២០.១១. អត្តសញ្ញាណប័ណ្ណចិន ចំនួន ០១(មួយ) សន្លឹក។

២០.១២. កាតធនាគារ ចំនួន ០១ (មួយ) សន្លឹក។

២០.១៣. កាតពណ៌ស ចំនួន ០១(មួយ) សន្លឹក។

២០.១៤. ប័ណ្ណបើកបរចិន ចំនួន ០១(មួយ)សន្លឹក។

២០.១៥. ព្រះរាជក្រឹត្យសញ្ជាតិខ្មែរឈ្មោះ[redacted] **ជីងឈីង** ចំនួន ០៩ (ប្រាំបួន) សន្លឹក។

២០.១៦. សៀវភៅគ្រួសារ ០១(មួយ)ក្បាល។

២០.១៧. ឯកសារផ្សេងៗមួយចំនួន។

តុលាការយល់ឃើញថា ទូរស័ព្ទដៃៈ ម៉ាក IPHONE XR ពណ៌ខ្មៅ, ម៉ាក IPHONE X ពណ៌ខ្មៅ និងម៉ាក IPHONE13 ពណ៌ខៀវ, ម៉ាក IPHONE 13 Pro Max ពណ៌ខៀវ និង ពណ៌ស្លែ, ម៉ាក IPHONE13 Pro Max ពណ៌ខៀវ, ម៉ាក IPHONE13 Pro Max ពណ៌ខៀវ និងម៉ាក IPHONE7 ពណ៌ខ្មៅ, ម៉ាក REDMI ពណ៌ខៀវ, ម៉ាក IPHONE13 ពណ៌ខៀវ និងពិលធក់ ចំនួន ០៤(បួន)គ្រឿង, ខ្នោះដៃ ចំនួន ០២(ពីរ)គូរ, កូនសោខ្នោះ ចំនួន ០២(ពីរ) ជាមធ្យោបាយនៃការប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស ដូចនេះគប្បីតុលាការសម្រេចរឹបអូស ស្របតាមបញ្ញត្តិនៃ**មាត្រា២២៩ ចំណុចទី៥ និងមាត្រា២៥៥ ចំណុចទី៥ នៃក្រមព្រហ្មទណ្ឌ** និង**មាត្រា៤៨ ចំណុច១ នៃច្បាប់ស្ដីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**។

តុលាការយល់ឃើញថា នាឡិកាដៃ ចំនួន ០២(ពីរ)គ្រឿង ម៉ាក LONGINES មានតួលោហៈពណ៌លឿង ខ្សែស្បែកពណ៌ខ្មៅ និងប្រាក់យ័ន្ត ចំនួន ៥០០(ប្រាំរយ)យ័ន្ត, ប្រាក់ ចំនួន ២២៣.០០០ (ពីររយម្ភៃបីពាន់)រៀល គឺជាទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ដូចនេះគប្បីតុលាការសម្រេចរឹបអូស ស្របតាមបញ្ញត្តិនៃ**មាត្រា២៥៥ ចំណុចទី៦ នៃក្រមព្រហ្មទណ្ឌ** និង**មាត្រា៤៨ ចំណុចទី៣ នៃច្បាប់ស្ដីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**។

តុលាការយល់ឃើញថា កាបូបលុយ ពណ៌ខ្មៅ ចំនួន ០១(មួយ), អត្តសញ្ញាណប័ណ្ណចិន ចំនួន ០១ (មួយ)សន្លឹក, កាតធនាគារ ចំនួន ០១ (មួយ) សន្លឹក, កាតពណ៌ស ចំនួន ០១(មួយ) សន្លឹក, ប័ណ្ណបើកបរចិន ចំនួន ០១(មួយ)សន្លឹក, ព្រះរាជក្រឹត្យសញ្ជាតិខ្មែរឈ្មោះ[redacted] **ជីងឈីង** ចំនួន ០៩ (ប្រាំបួន) សន្លឹក, សៀវភៅគ្រួសារ ០១(មួយ)ក្បាល, ឯកសារផ្សេងៗមួយចំនួន មិនមានជាប់ពាក់ព័ន្ធនឹងបទល្មើសឡើយ ដូចនេះគប្បីតុលាការសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ ស្របតាមបញ្ញត្តិនៃ**មាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ**។

២១. ជនជាប់ចោទឈ្មោះ[redacted] **BING LONG** ហៅ [redacted] **TIAN** ភេទប្រុស, ឈ្មោះ [redacted] **XIANG PING** ភេទប្រុស, ឈ្មោះ [redacted] **XIANG QUAN** ភេទប្រុស, ឈ្មោះ[redacted] **QIAO LONG** ភេទប្រុស, ឈ្មោះ[redacted] **LIN JIAN** ភេទប្រុស និងឈ្មោះ[redacted] **XIANKANG** ភេទប្រុស ជាជនបរទេសដែលមានពិរុទ្ធភាពចំពោះបទល្មើសដែលបានចោទប្រកាន់ ដូចនេះគប្បីតុលាការសម្រេចហាមឃាត់ជនជាប់ចោទខាងលើ ចំពោះការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាបណ្ដោះអាសន្នសម្រាប់រយៈពេល**០៤(បួន)ឆ្នាំ** នៅពេលបញ្ចប់ទោសដាក់ពន្ធ



Scanned with CamScanner

ពន្ធនាគារ ដោយអនុលោមតាមបញ្ញត្តិនៃ**មាត្រា៦១ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៨ ចំណុចទី៦ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**។

២២. ដោយអនុលោមតាមបញ្ញត្តិនៃមាត្រា៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៅក្នុងសាលក្រមតែមួយជាមួយរឿងព្រហ្មទណ្ឌ តុលាការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ប៉ុន្តែដើមបណ្ដឹងឈ្មោះ [redacted] JIA XU, ឈ្មោះ [redacted] YONG GUI និងឈ្មោះ [redacted] YAN មិនបានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ស្របទៅតាមមាត្រា១៣៧ និងមាត្រា៣១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដូចនេះគប្បីតុលាការមិនពិចារណាសម្រេចអំពីសំណងផ្នែករដ្ឋប្បវេណីឡើយ។

**សេចក្ដីសម្រេចបញ្ចប់**
**ហេតុដូច្នេះ សាលាដំបូងខេត្តព្រះសីហនុ**
**វិនិច្ឆ័យសេចក្ដី**

១. ឱ្យរួចខ្លួនពីបទចោទលើ៖

១.១. ឈ្មោះ [redacted] QIAO LONG ភេទប្រុស កើតឆ្នាំ១៩៩៣ ជនជាតិចិន (ដូចមានសាវតាជាតិខាងលើ) និង

១.២. ឈ្មោះ [redacted] LIN JIAN ភេទប្រុស កើតឆ្នាំ១៩៨៦ ជនជាតិចិន(ដូចមានសាវតាជាតិខាងលើ)

ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាម**មាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនជឹងឆាយ៥ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។

២. ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ៖

២.១. ឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN ភេទប្រុស កើតឆ្នាំ១៩៨៣ ជនជាតិចិន (ដូចមានសាវតាជាតិខាងលើ) ដាក់ពន្ធនាគារសរុបកំណត់ **១៨(ដប់ប្រាំបី)ឆ្នាំ**,

២.២. ឈ្មោះ [redacted] XIANG PING ភេទប្រុស កើតឆ្នាំ១៩៩៤ ជនជាតិចិន (ដូចមានសាវតាជាតិខាងលើ) ដាក់ពន្ធនាគារសរុបកំណត់ **១៧(ដប់ប្រាំពីរ)ឆ្នាំ** និង

២.៣. ឈ្មោះ [redacted] XIANG QUAN ភេទប្រុស កើតឆ្នាំ១៩៩១ ជនជាតិចិន (ដូចមានសាវតាជាតិខាងលើ) ដាក់ពន្ធនាគារសរុបកំណត់ **១៧(ដប់ប្រាំពីរ)ឆ្នាំ**

ពីបទ **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាម**មាត្រា២៥៣ ចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ**, បទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាម**មាត្រា២១៨ ចំណុចទី២ និងទី៣ នៃក្រមព្រហ្មទណ្ឌ** និងបទ **អំពើលក់ដូរមនុស្សដោយមានគោលដៅ** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាម**មាត្រា១៥ កថាខណ្ឌទី២ ចំណុចទី៣ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនជឹងឆាយ៥ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។

២.៤. ឈ្មោះ [redacted] QIAO LONG ភេទប្រុស កើតឆ្នាំ១៩៩៣ ជនជាតិចិន (ដូចមានសាវតាជាតិខាងលើ) ដាក់ពន្ធនាគារសរុបកំណត់ **១៥(ដប់ប្រាំ)ឆ្នាំ និង**៚



Scanned with CamScanner

២.៥. ឈ្មោះ [redacted] LIN JIAN ភេទប្រុស កើតឆ្នាំ១៩៨៦ ជនជាតិចិន (ដូចមានសាវតាជាតិខាងលើ) ដាក់ពន្ធនាគារសរុបកំណត់ **១៥(ដប់ប្រាំ)ឆ្នាំ**

ពីបទ **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម **មាត្រា២៥៣ ចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ** និងបទ **អំពើលក់ដូរមនុស្សដោយមានគោលដៅ** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា១៥ កថាខណ្ឌទី២ ចំណុចទី៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនជីងឆាយ៥ ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។

២.៦. ឈ្មោះ [redacted] XIANKANG ភេទប្រុស កើតឆ្នាំ១៩៨០ ជនជាតិចិន (ដូចមានសាវតាជាតិខាងលើ) ដាក់ពន្ធនាគារសរុបកំណត់ **១៧(ដប់ប្រាំពីរ)ឆ្នាំ**

ពីបទ **អំពើលក់ដូរមនុស្សដោយមានគោលដៅ** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម **មាត្រា១៥ កថាខណ្ឌទី២ ចំណុចទី៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ** និងបទ **សម្អាតប្រាក់** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម**មាត្រា៣៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម** ប្រព្រឹត្តនៅខេត្តព្រះសីហនុ កាលពីអំឡុងឆ្នាំ២០២២។

៣. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការបង្កកទ្រព្យសម្បត្តិ មានរថយន្តម៉ាក PORSCHE ពណ៌ខ្មៅ ពាក់ស្លាកលេខ: ភ្នំពេញ 2AG-0667 **ត្រូវសម្រេចរឹបអូស**។

៤. **រឹបអូសវត្ថុចាប់យក** រួមមាន៖

៤.១. ទូរស័ព្ទដៃចំនួន ០៣(បី)គ្រឿង មានម៉ាក IPHONE XR ពណ៌ខ្មៅ, ម៉ាក IPHONE X ពណ៌ខ្មៅ និងម៉ាក IPHONE13 ពណ៌ខៀវ។

៤.២. ទូរស័ព្ទដៃចំនួន ០២(ពីរ)គ្រឿង មានម៉ាក IPHONE 13 Pro Max ពណ៌ខៀវ និង ពណ៌ស្លែរ។

៤.៣. ទូរស័ព្ទដៃចំនួន ០១(មួយ)គ្រឿង មានម៉ាក IPHONE13 Pro Max ពណ៌ខៀវ។

៤.៤. ទូរស័ព្ទដៃចំនួន ០២(ពីរ)គ្រឿង មានម៉ាក IPHONE13 Pro Max ពណ៌ខៀវ និងម៉ាក IPHONE7 ពណ៌ខ្មៅ។

៤.៥. ទូរស័ព្ទដៃចំនួន ០២(ពីរ)គ្រឿង មានម៉ាក REDMI ពណ៌ខៀវ និងម៉ាក IPHONE13 ពណ៌ខៀវ។

៤.៦. ពិលឆក់ ចំនួន ០៤(បួន)គ្រឿង, ខ្នោះដៃ ចំនួន ០២(ពីរ)គូរ និងកូនសោខ្នោះ ចំនួន ០២(ពីរ)។

៤.៧. នាឡិកាដៃ ចំនួន ០២(ពីរ)គ្រឿង ម៉ាក LONGINES មានតួលោហៈពណ៌លឿង ខ្សែស្បែកពណ៌ខ្មៅ។

៤.៨. ប្រាក់យ័ន្ត ចំនួន ៥០០(ប្រាំរយ)យ័ន្ត, ប្រាក់រៀល ចំនួន ២២៣.០០០(ពីររយម្ភៃបីពាន់) រៀល។

៥. **ប្រគល់ឱ្យម្ចាស់ដើមវិញ** នូវវត្ថុចាប់យករួមមាន៖

៥.១. កាបូបលុយ ពណ៌ខ្មៅ ចំនួន ០១(មួយ)។

៥.២. អត្តសញ្ញាណប័ណ្ណចិន ចំនួន ០១(មួយ) សន្លឹក។

៥.៣. កាតធនាគារ ចំនួន ០១ (មួយ) សន្លឹក។

៥.៤. កាតពណ៌ស ចំនួន ០១(មួយ) សន្លឹក។

៥.៥. ប័ណ្ណបើកបរចិន ចំនួន ០១(មួយ)សន្លឹក។

៥.៦. ព្រះរាជក្រឹត្យសញ្ជាតិខ្មែរឈ្មោះ [redacted] **ជីងឈីង** ចំនួន ០៩ (ប្រាំបួន) សន្លឹក។/៚

៥.៧. សៀវភៅគ្រួសារ ០១(មួយ)ក្បាល។

៥.៨. ឯកសារផ្សេងៗមួយចំនួន។

៦. ហាមឃាត់ឈ្មោះ [redacted] LIN JIAN ភេទប្រុស, ឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN ភេទប្រុស, ឈ្មោះ [redacted] XIANG QUAN ភេទប្រុស, ឈ្មោះ [redacted] XIANG PING ភេទប្រុស, ឈ្មោះ [redacted] QIAO LONG ភេទប្រុស និងឈ្មោះ [redacted] XIANKANG ភេទប្រុស ស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាជាបណ្ដោះអាសន្ន សម្រាប់រយៈពេល **០៤(បួន)ឆ្នាំ** បន្ទាប់ពីអនុវត្តទោសពន្ធនាគារចប់ជាស្ថាពរ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នាថ្ងៃពុធ ៨កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] LIN JIAN ភេទប្រុស, ឈ្មោះ [redacted] BING LONG ហៅ [redacted] TIAN ភេទប្រុស, ឈ្មោះ [redacted] XIANG QUAN ភេទប្រុស, ឈ្មោះ [redacted] XIANG PING ភេទប្រុស និងឈ្មោះ [redacted] QIAO LONG ភេទប្រុស, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] XIANKANG ភេទប្រុស, កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នាថ្ងៃអង្គារ ៦កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ នៅសាលសវនាការនៃសាលាដំបូងខេត្តព្រះសីហនុ។

ភាគីដែលច្បាប់ផ្ដល់សិទ្ធិឱ្យ អាចប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៦កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦

ខេត្តព្រះសីហនុ, ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner